ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា

អគ្គលេខាធិការដ្ឋាន

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃការចុះវាយតម្លៃពីស្ថានភាពជាក់ស្តែង និង ការអនុវត្តស្តង់ដាជាតិសម្រាប់ការទទួលស្គាល់ គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា

## សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

២០១៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការ
ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
លេខ: ១០/១៦ គ.ទ.ក. ឥ៤ណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦

**ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**ជម្រាបជូន**

**សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ**

**កម្មវត្ថុ** : លទ្ធផលនៃការចុះវាយតម្លៃពីស្ថានភាពជាក់ស្តែង និង ការអនុវត្តស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

**យោង** :
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- សេចក្តីសម្រេចលេខ ០១/១៥ គ.ទ.ក.សសរ ចុះថ្ងៃទី២៦ មករា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- សេចក្តីណែនាំលេខ ៣១០៦ អយក.គទក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីដំណើរការនិងនីតិវិធីវាយតម្លៃពីស្ថានភាពជាក់ស្តែង និង ការអនុវត្តស្តង់ដាជាតិរបស់គ្រឹះស្ថានឧត្តមសិក្សា
- សេចក្តីជូនដំណឹងលេខ ២១៧៣ អយក.គទក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការចុះប្រមូលពត៌មាននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីជាមូលដ្ឋានក្នុងការចាប់ផ្តើមវាយតម្លៃគុណភាពអប់រំនៅឆ្នាំ២០១៦។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន សាកលវិទ្យាធិការ ជ្រាបថា លទ្ធផលនៃការចុះវាយតម្លៃពីស្ថានភាពជាក់ស្តែង និង ការអនុវត្តស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា នៅក្នុងឆ្នាំសិក្សា ២០១៤-២០១៥ បង្ហាញថា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានចំណុចខ្លាំង និងចំណុចខ្វះខាតមួយចំនួន ដូចមានក្នុងរបាយការណ៍ដែលភ្ជាប់មកជាមួយ។ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ អាចយកលទ្ធផលនៃការវាយតម្លៃនេះជាមូលដ្ឋានសម្រាប់កែលម្អការបណ្តុះបណ្តាលឲ្យកាន់តែល្អប្រសើរ ដើម្បីត្រៀមខ្លួនស្នើសុំការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជានាពេលខាងមុខ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម សាកលវិទ្យាធិការ ជ្រាប និង ចាត់ចែងតាមការគួរ ។ សូម ឯកឧត្តម សាកលវិទ្យាធិការ ទទួលនូវសេចក្តីគោរពរាប់អានអំពីខ្ញុំ

**ត.ប.ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**
**អគ្គលេខាធិការ**

ក.ទ.ក

**សាន មន្ថិយ៉ា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

អគ្គលេខាធិការដ្ឋាននៃ គ.ទ.ក

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃការចុះវាយតម្លៃពីស្ថានភាពជាក់ស្តែង និង ការអនុវត្តស្តង់ដារជាតិ សម្រាប់ការទទួលស្គាល់ គុណភាពអប់រំ លើគ្រឹះស្ថានឧត្តមសិក្សា

ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា : **សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ**

| | | |
|---|---|---|
| ឈ្មោះក្រុមមន្ត្រីវាយតម្លៃ : | លោក ឌៀប សីហា | ប្រធានក្រុម |
| | លោក វ៉ា មុនី | សមាជិក |
| | លោក ឈុន ណុច | សមាជិក |
| | បណ្ឌិត សូ សុធីរ | សមាជិក |
| | បណ្ឌិត ទេព មង្គល | សមាជិក |
| | វេជ្ជបណ្ឌិត អ៊ុក សាផៃ | សមាជិក |
| | លោក ឈាង សង្វាត | សមាជិក |
| | លោក វ៉ាន់ វុទ្ធា | មន្ត្រីសម្របសម្រួល |
| | កញ្ញា អ៊ុំ បូរមី | មន្ត្រីជំនួយការ |

**ថ្ងៃ ខែ ឆ្នាំចុះវាយតម្លៃ** : ពីថ្ងៃទី០៨-១៧ ខែមករា ឆ្នាំ២០១៦

# មាតិកា

ទំព័រ

I. សេចក្តីផ្តើម.......................................................................................៤

១. សាវត្តារបស់គ្រឹះស្ថានឧត្តមសិក្សា ...................................................................៤
២. គោលបំណងនៃការវាយតម្លៃ ........................................................................៤
II. ដំណើរការនិងនិតិវិធីវាយតម្លៃ.........................................................................៦

១. ការបែងចែកក្រុមការងារ..................................................................................៦
២. នីតិវិធីនៃការវាយតម្លៃ......................................................................................៦
៣. ទំហំ និងដែនកំណត់នៃការវាយតម្លៃ...................................................................៧
III. លទ្ធផលវាយតម្លៃស្តង់ដានីមួយៗដោយអនុក្រុមទាំងបី .......................................៩

ស្តង់ដា១ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ........................................................៩

ស្តង់ដា២អភិបាលកិច្ច និងការគ្រប់គ្រង.....................................................................១១

ស្តង់ដា៣ បុគ្គលិកអប់រំ...........................................................................................១៤

ស្តង់ដា៤ កម្មវិធីអប់រំ ............................................................................................២០

ស្តង់ដា៥ សេវានិស្សិត ...........................................................................................២៣

ស្តង់ដា៦ ធនធានសិក្សា .........................................................................................២៧

ស្តង់ដា៧ ធនធានរូបវន្ត...........................................................................................៣១

ស្តង់ដា៨ ធនធានហិរញ្ញវត្ថុ .....................................................................................៣៦

ស្តង់ដា៩ ការធានាគុណភាពផ្ទៃក្នុង ...........................................................................៣៩

IV. សេចក្តីសន្និដ្ឋានរួម .........................................................................................៤២

V. អនុសាសន៍........................................................................................................៤៥

## បញ្ជីពាក្យកាត់ តារាង ក្រាហ្វិក និងដ្យាក្រាម

គ.ទ.ក: គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

ស.ភ.ព.អ : សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

តារាងទី១ ស្ថិតិគ្រូបង្រៀនតាមវិស័យ និងតាមកម្រិតសញ្ញាបត្រ

តារាងទី ២ បង្ហាញពីស្ថិតិបន្ទប់ប្រជុំ និងបន្ទប់ការិយាល័យ

តារាងទី៣ បង្ហាញពីស្ថិតិសម្ភារៈរូបវន្ត

## I. សេចក្ដីផ្ដើម

### ១. សាវតាររបស់គ្រឹះស្ថានឧត្ដមសិក្សា

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានបង្កើតឡើងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៥៩ អនក្របក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០២ (មានឈ្មោះថាសាកលវិទ្យាល័យអាស៊ាន) និងបានប្ដូរឈ្មោះមកជា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ តាមអនុក្រឹត្យលេខ ១១១ អនក្របក ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៦។ ចាប់តាំងពីឆ្នាំ២០១០មក ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់លោកស្រី **ទេព កូលាប** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ទីតាំងសាកលវិទ្យាល័យត្រូវបានប្ដូរមកកាន់អាគារផ្ទាល់របស់ខ្លួន ដែលជាកម្មសិទ្ធរបស់**សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ** តាមអាសយដ្ឋានអគារលេខ៣៦ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ សាកលវិទ្យាល័យមានគ្រូបង្រៀនសរុបចំនួន ១៨១នាក់ ក្នុងនោះគ្រូបង្រៀនដែលមានកម្រិតសញ្ញាបត្របណ្ឌិតចំនួន៧នាក់ ត្រូវនឹង៤% មានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១៧១នាក់ ត្រូវនឹង៩៤% និង មានបរិញ្ញាបត្រចំនួន ៣នាក់ ត្រូវនឹង២%។

សាកលវិទ្យាល័យបណ្ដុះបណ្ដាលកម្រិតវិជ្ជាជីវៈរយៈពេលខ្លី កម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងកម្រិតបណ្ឌិត ដូចខាងក្រោម ៖

១. មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងទេសចរណ៍

- ជំនាញគ្រប់គ្រង
- ជំនាញទីផ្សារ
- ជំនាញគណនេយ្យ
- ជំនាញគ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍

២. មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច

- ជំនាញហិរញ្ញវត្ថុ និងធនាគារ
- ជំនាញសេដ្ឋកិច្ច
- ជំនាញច្បាប់
- ជំនាញរដ្ឋបាលសាធារណៈ

៣.មហាវិទ្យាល័យវិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា

- ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ
- ជំនាញគ្រប់គ្រងព័ត៌មានវិទ្យា
- ជំនាញគណិតវិទ្យា

៤.មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ

- ជំនាញភាសាអង់គ្លេសអប់រំ
- ជំនាញភាសាអង់គ្លេសសម្រាប់ពាណិជ្ជសាស្ត្រ

ជាមួយគ្នានេះដែរសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានបណ្តុះបណ្តាលកម្រិតក្រោយបរិញ្ញាបត្រមួយចំនួនទៀតដូចជា :

- ថ្នាក់ក្រោយបរិញ្ញាបត្រ
  - ក-កម្រិតបរិញ្ញាបត្រជាន់ខ្ពស់
    - -ហិរញ្ញវត្ថុ និងធនាគារ
    - -គ្រប់គ្រង
    - -ទីផ្សារ
    - -វិទ្យាសាស្ត្រកុំព្យូទ័រ
    - -វិទ្យាសាស្ត្រអប់រំ
  - ខ-កម្រិតបណ្ឌិត
    - -គ្រប់គ្រង

## ២. គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃនេះ មានគោលបំណងពិនិត្យពីស្ថានភាពជាក់ស្តែង និងការអនុវត្តស្តង់ដាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំ របស់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ លទ្ធផលនៃការវាយតម្លៃនេះនឹងយកមកប្រើប្រាសជា ព័ត៌មានផ្ទៃក្នុង និង ជាមូលដ្ឋានក្នុងការសម្រេចចិត្តលើការកែលម្អបទដ្ឋានសម្រាប់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និង ការចាប់ផ្តើមចុះវាយតម្លៃគុណភាពអប់រំនៅឆ្នាំ ២០១៦។ លទ្ធផលនៃការវាយតម្លៃនេះនឹងមិនត្រូវបានយកមកប្រើប្រាស់សម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំ ឬ ធ្វើចំណាត់ថ្នាក់លើគ្រឹះស្ថានឧត្តមសិក្សាដែលត្រូវបានវាយតម្លៃឡើយ។

## II. វិធីសាស្ត្រនិងដំណើរការនៃការវាយតម្លៃ

### ១. ការបែងចែកក្រុមការងារ

ដើម្បីធានាបានប្រសិទ្ធភាព តម្លាភាព និងសុក្រិតភាពនៃដំណើរការ និងលទ្ធផល នៃការវាតម្លៃ មន្ត្រីវាយតម្លៃទាំងប្រាំពីររូប ត្រូវបានបែងចែកជាបីអនុក្រុមតូចៗទទួលបន្ទុកស្តង់ដានីមួយៗដែលមានសមាសភាពដូចខាងក្រោមៈ

១. សមាជិកអនុក្រុមទី១ (ទទួលបន្ទុកស្តង់ដាទី១, ២ និង៨)

- លោក ឌៀប សីហា
- លោក វ៉ា មុនី

២. សមាជិកអនុក្រុមទី២ (ទទួលបន្ទុកស្តង់ដាទី៣,៤ និង៦)

- លោក ឈុន ណុច
- បណ្ឌិត សូ សុធីរ
- បណ្ឌិត ទេព មង្គល

៣. សមាជិកអនុក្រុមទី៣ (ទទួលបន្ទុកស្តង់ដាទី៥,៧ និង៩)

- វេជ្ជបណ្ឌិត អ៊ុក សាផៃ
- លោក ឈាង សង្វាត

៤. មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ទ.ក

- លោក វ៉ាន់ វុទ្ធា មន្ត្រីសម្របសម្រួល
- កញ្ញា អ៊ុំ បូរមី មន្ត្រីជំនួយការ

### ២. នីតិវិធីនៃការវាយតម្លៃ

- **ដំណាក់ទី១ៈ** ក្រុមមន្ត្រីវាយតម្លៃបានសិក្សាឯកសារ និងរបាយការណ៍ស្វ័យវាយតម្លៃដែលធ្វើឡើងជាពីរវគ្គ។ វគ្គទីមួយគឺការសិក្សាលើរបាយការណ៍ស្វ័យវាយតម្លៃរបស់សាកលវិទ្យាល័យ វគ្គទីពីរ គឺការសិក្សាលើឯកសារគាំទ្រផ្សេងៗរបស់សាកលវិទ្យាល័យ
- **ដំណាក់ទី២ៈ** ក្រុមមន្ត្រីវាយតម្លៃបានចុះវាយតម្លៃលើការអនុវត្តផ្ទាល់គ្រឹះស្ថានឧត្តមសិក្សា តាមរយៈការសម្ភាសន៍ ការពិភាក្សា និងការសង្កេត ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបាយការណ៍ស្វ័យវាយតម្លៃ ជាមួយនឹងការអនុវត្តជាក់ស្តែងរបស់សាកលវិទ្យាល័យ
- **ដំណាក់ទី៣ៈ** ក្រុមមន្ត្រីវាយតម្លៃបានធ្វើការបូកសរុបលើលទ្ធផលនៃការវាយតម្លៃ និងរៀបចំរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាន គ.ទ.ក ដើម្បីពិនិត្យនិងដាក់ជូនរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ដើម្បីពិនិត្យ និងសម្រេច។

## ៣. ទំហំ និងដែនកំណត់នៃការវាយតម្លៃ

ការសិក្សាវាយតម្លៃលើគុណភាពអប់រំរបស់ ស.ភ.ព.អ ត្រូវបានអនុវត្តដោយប្រើប្រាស់ស្តង់ដាគុណភាពអប់រំឧត្តមសិក្សា ដែលបានដាក់អោយប្រើប្រាស់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃ កម្ពុជា។ ការប្រមូលទិន្នន័យ ការវិភាគនិងបកស្រាយ ធ្វើឡើងដោយផ្អែកលើសមត្ថភាពនិងបទពិសោធន៍របស់ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំ ដែលមានចំនួន ៩រូប ដែលក្នុងនោះមានមន្ត្រីវាយតម្លៃ ៧រូប មន្ត្រីសម្របសម្រួល១រូប និងមន្ត្រីជំនួយការ១រូប ហើយប្រើប្រាស់ពេលវេលាចំនួន១០ថ្ងៃ។

យោងតាមពេលវេលាកំណត់ និងស្ថានភាពអប់រំរបស់ ស.ភ.ព.អ ក្រុមមន្ត្រីវាយតម្លៃបានកំណត់យកទំហំនៃការវាយតម្លៃនៅសាកលវិទ្យាល័យជាក់ស្តែងដែលមានអាស័យដ្ឋានដែលមានទីតាំងស្ថិតនៅ អគារលេខ៣៦ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## ៤.ដំណើរការនៃការវាយតម្លៃរយះពេល១០ថ្ងៃ( ៨-១៧ ខែមករា ឆ្នាំ២០១៦ )

ដំណើរការ និង សកម្មភាពវាយតម្លៃនៃក្រុមមន្ត្រីវាយតម្លៃក្នុងរយះពេល១០ថ្ងៃនេះត្រូវបានអនុវត្តជាបី តំណាក់កាលធំៗដូចរៀបរាប់លម្អិតខាងក្រោមៈ

### ក.ដំណាក់កាលទី១ៈ ពីថ្ងៃទី៨ដល់ ថ្ងៃទី១០ខែមករាឆ្នាំ២០១៦

សិក្សារបាយ ការណ៍ ស្វ័យវាយតម្លៃនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ទ.ក និង នៅសាកលវិទ្យាល័យ។

### ខ.ដំណាក់កាលទី២ៈ ពីថ្ងៃទី១១ដល់ ថ្ងៃទី១៥ខែមករាឆ្នាំ២០១៦

ក្រុមមន្ត្រីវាយតម្លៃបានចុះពិនិត្យជាក់ស្តែងនិងធ្វើការវាយតម្លៃនៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិដែលមានទីតាំងស្ថិតនៅ អគារលេខ៣៦ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានី ភ្នំពេញ។ ក្នុងរយះពេល៥ថ្ងៃនេះក្រុមមន្ត្រីវាយតម្លៃ និង មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ទ.ក បានដំណើរការសកម្មភាពការងាររួមមានការប្រជុំជាមួយថ្នាក់ដឹកនាំ និង អ្នកពាក់ពន្ធ័ ការពិនិត្យទីកន្លែងជាក់ស្តែង ការសិក្សាឯកសារ និង ជួបសំភាសន៍ជាមួយអ្នកពាក់ពន្ធ័ តាមនីមួយៗដូចពន្យល់សង្ខេបខាងក្រោមៈ

- **សកម្មភាពថ្ងៃទី១ ( ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ )**: ការជួបប្រជុំជាមួយគណៈគ្រប់គ្រងនិងមន្ត្រីពាក់ពន្ធ័នៃគ្រឹះស្ថានឧត្តមសិក្សា ស្តាប់បទបង្ហាញរបាយការណ៍សង្ខេបស្តីពីស្ថានភាពទូរទៅរបស់គ្រឹះស្ថាន។

- សកម្មភាពថ្ងៃទី១២ ( ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ): មន្ត្រីវាយតម្លៃពិនិត្យ ផ្ទៀងផ្ទាត់និង សិក្សារបាយការណ៍និងឯកសារពាក់ពន្ធ័លើស្តង់ដាទាំង៩។
- សកម្មភាពថ្ងៃទី៣ ( ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ): មន្ត្រីវាយតម្លៃជួបសម្ភាសន៍ជាមួយនិស្សិតកម្រិតបរិញ្ញាបត្រ និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ពាក់ពន្ធ័នឹងសកម្មភាពសិក្សាស្រាវជ្រាវ សកម្មភាពសហគមន៍ គោលនយោបាយ និងសេវាកម្មគាំទ្រដល់សកម្មភាពសិក្សាស្រាវជ្រាវរបស់និស្សិតជាច្រើនទៀត។ មន្ត្រីវាយតម្លៃក៏បានចុះពិនិត្យសកម្មភាពបង្រៀនរបស់គ្រូនិង សកម្មភាពសិក្សារបស់និស្សិតក្នុងបន្ទប់រៀនជាក់ស្តែង និង បានធ្វើការសម្ភាសន៍ជាមួយជាមួយគ្រូបង្រៀនផងដែរ ដើម្បីស្វែងយល់ពីសកម្មភាពស្រាវជ្រាវនិងសកម្មភាពពាក់ពន្ធ័ជាច្រើនទៀតជាមួយគ្រឹះស្ថាន។
- សកម្មភាពថ្ងៃទី៤ ( ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ): មន្ត្រីវាយតម្លៃចុះពិនិត្យផ្ទៀងផ្ទាត់និង វាយតម្លៃមូលដ្ឋានសម្ភារៈបម្រើឲ្យសកម្មភាពសិក្សាស្រាវជ្រាវ ការបង្រៀន និង សកម្មភាពជាច្រើនទៀតពាក់ពន្ធ័នឹងការសិក្សាស្រាវជ្រាវទាំងក្នុងនិងក្រៅសាកល វិទ្យាល័យ។
- សកម្មភាពថ្ងៃទី៥ ( ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ): មន្ត្រីវាយតម្លៃប្រជុំបូកសរុបលទ្ធផលនៃស្តង់ដានីមួយៗ និង លទ្ធផលអនុក្រុមក្រោយពីការសិក្សាវាយតម្លៃរបាយការណ៍ ឯកសារពាក់ព័ន្ធផ្សេងៗ និង ការចុះពិនិត្យផ្ទាល់លើសកម្មភាពបណ្តុះបណ្តាល សិក្សាស្រាវជ្រាវ និងមូលដ្ឋានសម្ភារៈគាំទ្រដល់សកម្មភាពសិក្សាស្រាវជ្រាវនៃគ្រឹះស្ថានទាំងមូល។ ចុងបញ្ចប់នៃអង្គប្រជុំមន្ត្រីវាយតម្លៃទាំងអស់ឯកភាពលើលទ្ធផលបឋម និង រៀបចំបទបង្ហាញពីលទ្ធផលសង្ខេបនៃការវាយតម្លៃលើស្តង់ដាទាំង៩ និង រៀបចំការជួបប្រជុំជាមួយគណៈគ្រប់គ្រង និង មន្ត្រីពាក់ពន្ធ័នៃគ្រឹះស្ថានដើម្បីរាយការណ៍ដោយសង្ខេបពីលទ្ធផលបឋមនេះ និងទុកឱកាសឲ្យតំណាងគ្រឹះស្ថាន និងអ្នកពាក់ពន្ធ័បានលើកភស្តុតាង និងសេចក្តីបញ្ជាក់បន្ថែមលើចំនុចខ្វះខាត សំណូមពរ និងអនុសាសន៍តាមស្តង់ដានីមួយៗ ដែលប្រធានក្រុមមន្ត្រីវាយបានធ្វើបទបង្ហាញ។ សូមមើលសកម្មភាពលម្អិតនៃសកម្មភាពដំណាក់កាលទី២នេះក្នុងឧបសម្ព័ន្ធ៣ ។

**គ.ដំណាក់កាលទី៣៖ ពីថ្ងៃទី១៦ដល់ ថ្ងៃទី១៧ខែមករាឆ្នាំ២០១៦**

បូកសរុបលទ្ធផលនៃការវាយតម្លៃស្តង់ដាទាំង៩ និង រៀបចំរបាយការណ៍ដាក់ជូន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។ ក្រោយពីការជួបប្រជុំបង្ហាញលទ្ធផលបឋមដល់ថ្នាក់ដឹកនាំគ្រឹះស្ថាន ក្រុមមន្ត្រីវាយតម្លៃពិនិត្យ ឡើងវិញលើស្តង់ដារ ទទួលបន្ទុកនីមួយៗនិងអាចធ្វើការកែតម្រូវលើចំណុចខ្វះខាត សំណូមពរ និង អនុសាសន៍យោងតាមការចាំបាច់នៃលទ្ធផលអង្គប្រជុំ។ លទ្ធផលចុងក្រោយនៃស្តង់ដា របស់មន្ត្រីវាយតម្លៃម្នាក់ៗ និង លទ្ធផលអនុក្រុមទាំងបីត្រូវបានរៀបចំពិនិត្យ ផ្ទៀងផ្ទាត់ចុងក្រោយ និង ប្រគល់ជូនប្រធានក្រុមមន្ត្រីវាយ ដើម្បីរៀបចំធ្វើ របាយការណ៍រួមនៃស្តង់ដាទាំង៩ដាក់ជូន គ.ទ.ក ។

## II. លទ្ធផលនៃការវាយតម្លៃ

### ស្តង់ដា១: ចក្ខុវិស័យ បេសកកម្ម និងគោលដៅ

ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សាកំណត់ពីលក្ខណៈ ប្រភេទសកម្មភាពអប់រំ និងតួនាទីរបស់គ្រឹះស្ថានឧត្តមសិក្សា ក្នុងវិស័យអប់រំឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងចំបងនៃការវាយតម្លៃលើស្តង់ដាទី១នេះ គឺសំដៅស្វែងយល់ និងវិភាគអំពីភាពច្បាស់លាស់ ភាពសមស្រប និង ភាពត្រឹមត្រូវ នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សា ដែលបានផ្សព្វផ្សាយជាសាធារណៈ។

១.ការបំពេញតាមសូចនាករ

**១.១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅ មានការឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងកិច្ចការពារ ការថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានពិណ៌នាអំពីចក្ខុវិស័យ បេសកកម្ម និង គោលដៅមានការឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ តំបន់ និង អន្តរជាតិ យោងតាមរបាយការណ៍ ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តឆ្នាំ២០១១-២០១៥ "ទំព័រ១១ ល.រ.៨" និងបានរៀបចំផែន ការយុទ្ធសាស្រ្តថ្មីសម្រាប់ឆ្នាំ ២០១៦-២០២០)និងមានរបាយការណ៍និងកំណត់ហេតុការប្រជុំស្តីពីការអភិវឌ្ឍចក្ខុវិស័យ បេសកកម្ម និង គោលដៅរបស់ខ្លួន(ក្នុងរបាយការណ៍ប្រជុំការងារគណៈគ្រប់គ្រង ស.ភ.ព.អ ចុះថ្ងៃទី១៩ ធ្នូ ២០១៥) ជាមួយគ្នានេះ ក៏មានរបាយការណ៍ ស្តីពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និង គោលដៅ (ក្នុងរបាយការណ៍សង្ខេបសកម្មភាពការងារឆ្នាំ២០១១-១២, ២០១២-១៣, ២០១៣-១៤ និងឆ្នាំ២០១៤-១៥)។

**១.២. គ្រឹះស្ថានឧត្តមសិក្សាពិនិត្យ និងកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលដៅក្នុង ទៀងទាត់ ដើម្បីវាយតម្លៃអំពីភាពពាក់ព័ន្ធ និងភាពចាំបាច់នៃចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា**

ស.ភ.ព.អ បានរៀបចំជាយន្តការសម្រាប់ការតាមដាន និងការវាយតម្លៃផ្ទៃក្នុង (ក្នុងផែនការយុទ្ធសាស្រ្ត "ទំព័រ២៤" និងក្នុងយុទ្ធសាស្រ្តឆ្នាំ២១៤-១៥ "ទំព័រ១៦") ដោយមានរបាយការណ៍ ស្តីពីការពិនិត្យឡើងវិញសម្រាប់ការអនុវត្តចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ខ្លួន(របាយការណ៍ ចុះថ្ងៃទី១៨ ធ្នូ ២០១៤)។

**១.៣. គ្រឹះស្ថានឧត្តមសិក្សា ផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងគោលដៅ បានទូលំទូលាយដល់សមាជិកគ្រឹះស្ថាន និងផ្សព្វផ្សាយតាមរយៈការបោះពុម្ព និងគេហទំព័ររបស់គ្រឹះស្ថាន**

ស.ភ.ព.អ មានរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយដល់សមាជិក និង ភាគីពាក់ព័ន្ធ (ក្នុងរបាយការណ៍ ស្តីពីការបើកបវេសនកាលថ្មីឆ្នាំ២០១៥-១៦ "ចុះថ្ងៃទី២៣ វិច្ឆិកា ២០១៥") និង បានរៀបចំឯកសារបោះពុម្ពផ្សាយរួមមានៈ សៀវភៅណែនាំ ខិតប័ណ្ណ កាតាឡុក និង គេហទំព័ររបស់ខ្លួនសម្រាប់ការដំណើរការការងារអប់រំឧត្តមសិក្សាទៅតាមជំនាញដែលបានដាក់ចេញ។

## ២. សេចក្តីសន្និដ្ឋាន

គ្រប់ភស្តុតាងទាំងអស់ដែលបានបញ្ជាក់លើសូចនាករនីមួយៗខាងលើ គឺជាទិន្នន័យជាក់ស្តែងដែលបានមកពីការពិនិត្យផ្ទាល់ តាមរយៈការសិក្សាឯកសារ ការសាកសួរមន្ត្រី និងអ្នកពាក់ព័ន្ធនានា។ ផ្អែកតាមលទ្ធផលទាំងអស់នេះអនុក្រុមអាចវិភាគថា សាកលវិទ្យាល័យមានការពិណ៌នាអំពីចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ខ្លួន អាចឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ ក្នុងតំបន់ និងអន្តរជាតិ ដោយមានការចូលរួមចំណែកការពារ ថែរក្សាវប្បធម៌ និង អត្តសញ្ញាណជាតិ។ ស.ភ.ព.អ បានរៀបចំជាយន្តការសម្រាប់ការតាមដាន និង ការវាយតម្លៃផ្ទៃក្នុងដោយមានរបាយការណ៍ស្តីពីការពិនិត្យឡើងវិញសម្រាប់ការអនុវត្តចក្ខុវិស័យ បេសកកម្ម និង គោលដៅរបស់ខ្លួន។ ស.ភ.ព.អ មានរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយដល់សមាជិកនិងភាគីពាក់ព័ន្ធ និង បានរៀបចំឯកសារបោះពុម្ពផ្សាយរួមមានៈ

សៀវភៅណែនាំ ខិតប័ណ្ណ កាតាឡុក និង គេហទំព័ររបស់ខ្លួន សម្រាប់ការដំណើរការការងារអប់រំ ឧត្តមសិក្សាទៅតាមជំនាញដែលបានដាក់ចេញ។ ទន្ទឹងនឹងមានចំណុចខ្លាំងទាំងអស់ខាងលើ សាកលវិទ្យាល័យក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរមានដូចខាងក្រោមៈ

ស.ភ.ព.អ នៅពុំទាន់បានបង្ហាញ ឬបញ្ជាក់ ឬកំណត់ច្បាស់លាស់ អំពីកាលបរិច្ឆេទ ឈ្មោះ ហត្ថលេខី ការប្រថាប់ត្រា ឬ ចុះលេខទំព័រលើឯកសារពាក់ព័ន្ធមួយចំនួនដែលមានស្រាប់ដើម្បីបញ្ជាក់ជាឯកសារស្របតាមបែបបទលក្ខណៈរដ្ឋបាលនៅឡើយ។

## ៣. អនុសាសន៍

ដើម្បីកែលម្អការអនុវត្តស្តង់ដានេះឲ្យកាន់តែប្រសើរ ស.ភ.ព.អ ត្រូវបំពេញអនុសាសន៍ ដូចខាងក្រោមៈ

១.សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅមានចំណុចខ្វះខាតខ្លះៗដែលគួរបំពេញបន្ថែម និងកែលម្អ គឺគួរតែបញ្ជាក់ ឬកំណត់ឱ្យបានច្បាស់លាស់ អំពីកាលបរិច្ឆេទ ឈ្មោះហត្ថលេខី ប្រថាប់ត្រា ឬ ចុះលេខទំព័រលើឯកសារពាក់ព័ន្ធមួយចំនួនដែលមានស្រាប់ សម្រាប់ដំណើរការការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងជាឯកសារផ្លូវការ។

## ស្តង់ដា២: អភិបាលកិច្ច និងការគ្រប់គ្រង

ដើម្បីសម្របសម្រួលដល់ការបំពេញតួនាទីឲ្យកាន់តែមានប្រសិទ្ធភាព និង ដើម្បីធានាសម្រេចបានលទ្ធផលល្អ គ្រឹះស្ថានឧត្តមសិក្សាចាំបាច់ត្រូវមានគោលនយោបាយអភិបាលកិច្ចល្អ និងរដ្ឋបាលច្បាស់លាស់ ហើយអាចអនុវត្តបាន។ គោលបំណងចំបងនៃការវាយតម្លៃលើស្តង់ដាទី២នេះ គឺសំដៅស្វែងយល់និងវិភាគអំពីរចនាសម្ព័ន្ធនិងតួនាទីភារកិច្ចនៃក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធគ្រប់ គ្រងនិងប្រព័ន្ធរដ្ឋបាល គុណវុឌ្ឍិនិងបទពិសោធន៍របស់មន្ត្រីគ្រប់គ្រង ដែលជាកត្តាជួយធានាការសម្រេចចក្ខុវិស័យ បេសសកម្មនិង គោលដៅ របស់សកលវិទ្យាល័យ។

### ១. ការបំពេញតាមសូចនាករ

### ១.១. គ្រឹះស្ថានឧត្តមសិក្សា មានរចនាសម្ព័ន្ធច្បាស់លាស់ដែលបង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារក្នុងគ្រឹះស្ថាន

ស.ភ.ព.អ មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ដោយបានបញ្ជាក់ឈ្មោះបុគ្គលិកនៅក្នុងមុខតំណែង និងមានការទំនាក់ទំនងការងារនីមួយៗទៅតាមភារកិច្ចទទួលខុសត្រូវរបស់ខ្លួន (ទំព័រ២៦ ក្នុងភស្តុតាងស្តង់ដា១)។

### ១.២. គ្រឹះស្ថានឧត្តមសិក្សា កំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលច្បាស់លាស់ ដោយអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធ

ស.ភ.ព.អ មានគោលការណ៍និងការពិពណ៌នាអំពីតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល (ក្នុងយុទ្ធសាស្ត្រ សម្រាប់ឆ្នាំសិក្សា២០១១-១៥ លេខរៀងលេខទី១០ ទំព័រ២០ ក្នុងភស្តុតាងស្តង់ដា១) និងមានលក្ខណាវិនិច្ឆ័យ ដំណើរការ និង សេចក្តីសម្រេចតែងតាំងក្រុមប្រឹក្សាភិបាល (សេចក្តីសម្រេចលេខ: ២១៨/១៤ ស.ភ.ព.អ ចុះថ្ងៃទី១៦ មិថុនា ២០១៤) ដោយមាននីតិវិធីជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល (ក្នុងរបាយការណ៍ប្រជុំជ្រើសរើស ចុះថ្ងៃទី១៦ ឧសភា ២០១៤)។ ស.ភ.ព.អ មានលិខិតតែងតាំងនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាច្បាស់លាស់(ក្នុងបទបញ្ញត្តិក្រុមប្រឹក្សាភិបាល "គោលការណ៍មូលដ្ឋាន" ចុះថ្ងៃទី១៨ មករា ២០១០)។

## ១.៣. ការអភិវឌ្ឍន៍របស់គ្រឹះស្ថានមានសង្គតិភាពជាមួយនឹង ចក្ខុវិស័យ បេសកកម្មនិងគោលដៅដែលបានកំណត់

ស.ភ.ព.អ មានផែនការយុទ្ធសាស្ត្រស្របទៅនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅ (ក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ "ក្នុងទំព័រ១១ល.រ.៨" និង បានរៀបចំផែនការយុទ្ធសាស្ត្រថ្មីឆ្នាំ២០១៦-២០២០) ហើយបានកំណត់ផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន (ក្នុងរបាយការណ៍សង្ខេបសកម្មភាពការងារ សម្រាប់ឆ្នាំ២០១១-១២, ២០១២-១៣, ២០១៣-១៤ និង ឆ្នាំ២០១៤-១៥) ដោយមានយន្តការសម្រាប់ការតាមដាន និង របាយការណ៍ ស្តីពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។

## ១.៤. បុគ្គលិករដ្ឋបាលមានគុណវុឌ្ឍិ សមត្ថភាព និង បទពិសោធន៍ ស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ

ស.ភ.ព.អ មានកំណត់តួនាទីភារកិច្ចបុគ្គលិករដ្ឋបាលដែលមានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍ស្របទៅនឹងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន (ក្នុងបញ្ជីរាយនាមគណៈគ្រប់គ្រង បុគ្គលិក កំពុងបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ចុះថ្ងៃទី០៩ ធ្នូ ២០១៥) និង មានបញ្ជីប្រវត្តិរូបសញ្ញាបត្រ និងលិខិតបញ្ជាក់ (ក្នុងបញ្ជីរាយនាមគណៈគ្រប់គ្រង បុគ្គលិក កំពុងបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ចុះថ្ងៃទី០៩ ធ្នូ ២០១៥)។ ស.ភ.ព.អ មានលក្ខខណ្ឌតម្រូវក្នុងការជ្រើសរើសបុគ្គលិកត្រឹមត្រូវ (Job Opportunity No: 125/2015. PPIU) និងមានឯកសារវាយតម្លៃលើការបំពេញការងារ (ក្នុងឧបសម្ព័ន្ធ៣ស្តីពីការងារចាំបាច់ដែលត្រូវបំពេញ ឆ្នាំសិក្សា២០១១-១២)និងកិច្ចសន្យាបម្រើការងាររបស់បុគ្គលិក/និយោជិតពេញសិទ្ធិរបស់ ស.ភ.ព.អ។

## ១.៥. តួនាទីនិងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដាច់ដោយឡែកពីតួនាទី និងភារកិច្ចនៃកិច្ចការរដ្ឋបាលនិងកិច្ចការតាមមហាវិទ្យាល័យ

ស.ភ.ព.អ មានគោលការណ៍ និងបទបញ្ញត្តិសម្រាប់ក្រុមប្រឹក្សាភិបាល (ក្នុងបទបញ្ញត្តិសម្រាប់និយោជិត ចុះថ្ងៃ ទី០២ មេសា ២០១៤) និងមានកំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល (របាយការណ៍ប្រជុំក្រុមប្រឹក្សា ចុះថ្ងៃទី១៨ មករា ២០១០)។ ស.ភ.ព.អ មានការតែងតាំងក្រុមប្រឹក្សាភិបាល (លេខៈ ២១៨/១៤ ស.ភ.ព.អ ចុះថ្ងៃទី១៦ មិថុនា ២០១៤) និងសៀវភៅ/សេចក្តីណែនាំ អំពីតួនាទីភារកិច្ចសមាជិកក្រុមប្រឹក្សាភិបាលបុគ្គលិករដ្ឋបាល គ្រូបង្រៀន និងបុគ្គលិកពាក់ព័ន្ធនានា (ក្នុងផ្នែកៈ គ្រប់គ្រង "សេចក្តីណែនាំអំពីការងារ និងភារកិច្ច" ចុះថ្ងៃទី១៨ មករា ២០១០)។

## ១.៦. ក្រុមប្រឹក្សាភិបាល វាយតម្លៃប្រសិទ្ធភាពនៃការងាររបស់ខ្លួនដោយទៀងទាត់

ស.ភ.ភ.ពពុំទាន់បានធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការវាយតម្លៃការអនុវត្តការងារ របស់ក្រុមប្រឹក្សាភិបាល នៅឡើយ។

## ២. សេចក្តីសន្និដ្ឋាន

គ្រប់ភស្តុតាងទាំងអស់ដែលបានបញ្ជាក់លើសូចនាករនីមួយៗខាងលើ គឺជាទិន្នន័យជាក់ស្តែងដែលបានមកពីការពិនិត្យផ្ទាល់តាមរយៈការសិក្សាឯកសារ ការសាកសួរមន្ត្រី និង អ្នកពាក់ព័ន្ធនានា។ ផ្អែកតាមលទ្ធផលទាំងអស់នេះ អនុក្រុមអាចវិភាគថា ស.ភ.ព.អ មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ដោយបានបញ្ជាក់ ឈ្មោះបុគ្គលិកនៅក្នុងមុខតំណែង និង មានការទំនាក់ទំនងការងារនីមួយៗទៅតាមភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ហើយបង្កើតឱ្យមានគោលការណ៍ និងការពិពណ៌នាអំពីតួនាទី ភារកិច្ចក្រុមប្រឹក្សាភិបាល និងមានលក្ខណវិនិច្ឆ័យដំណើរការ និងសេចក្តីសម្រេច តែង តាំងក្រុមប្រឹក្សាភិបាលដោយមាននីតិវិធីជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល។ ស.ភ.ព.អ មានលិខិតតែងតាំងនិងបទបញ្ជាផ្ទៃ ក្នុង របស់ក្រុមប្រឹក្សា ច្បាស់ លាស់របស់ខ្លួន។

ស.ភ.ព.អ មានផែនការយុទ្ធសាស្ត្រស្របទៅនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅ ហើយបានកំណត់ផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ដោយមានយន្តការសម្រាប់ការតាមដាន និង របាយការណ៍ ស្តីពីការអនុវត្តផែន ការសកម្មភាពរបស់ខ្លួន។ ជាមួយគ្នានេះបានកំណត់តួនាទីភារកិច្ចបុគ្គលិករដ្ឋបាលដែលមានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍ស្របទៅនឹងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន បញ្ជីរាយនាមគណៈគ្រប់គ្រង បុគ្គលិក កំពុងបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងមានបញ្ជីប្រវត្តិរូប សញ្ញាបត្រ និងលិខិតបញ្ជាក់។ ស.ភ.ព.អ មានលក្ខខណ្ឌ តម្រូវក្នុង ការជ្រើសរើសបុគ្គលិកត្រឹមត្រូវ និងឯកសារវាយតម្លៃលើការបំពេញការងារ ដោយមានកិច្ចសន្យា បម្រើ ការងាររបស់បុគ្គលិក/និយោជិតពេញសិទ្ធិរបស់ ស.ភ.ព.អ។

ស.ភ.ព.អ មានគោលការណ៍ និងបទបញ្ញត្តិសម្រាប់ក្រុមប្រឹក្សាភិបាល និងមានកំណត់ហេតុអង្គប្រជុំ ក្រុមប្រឹក្សាភិបាល ហើយមានការតែងតាំងក្រុមប្រឹក្សាភិបាល និងសៀវភៅ / សេចក្តីណែនាំ អំពីតួនាទីភារកិច្ចសមាជិកក្រុមប្រឹក្សាភិបាលបុគ្គលិករដ្ឋបាល គ្រូបង្រៀន និងបុគ្គលិកពាក់ព័ន្ធនានា។

ស.ភ.ព.អ បានធ្វើរបាយការណ៍ប្រចាំឆ្នាំ២០១៥ ឆ្នាំ២០១៤ និងឆ្នាំ២០១៣ ស្តីពីការវាយតម្លៃការអនុវត្តការងារក្រុមប្រឹក្សាភិបាលរបស់ខ្លួន។ ទន្ទឹមនឹងមានចំណុចខ្លាំងទាំងអស់ខាងលើ សាកលវិទ្យាល័យក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ មានដូចខាងក្រោម៖

១. ស.ភ.ព.អ នៅពុំទាន់មានរបាយការណ៍ប្រចាំឆ្នាំ២០១២ និងឆ្នាំ២០១១ ស្តីពីការវាយតម្លៃលើការអនុវត្តការងាររបស់ក្រុមប្រឹក្សា ភិបាលរបស់ខ្លួន។

២. ស.ភ.ព.អ នៅមានការខ្វះចន្លោះខ្លះៗដោយពុំទាន់បានបញ្ជាក់ ឬកំណត់ច្បាស់លាស់ អំពីកាលបរិច្ឆេទ ឈ្មោះហត្ថលេខី ការប្រថាប់ត្រា ឬចុះលេខទំព័រលើឯកសារពាក់ព័ន្ធមួយចំនួនដែលមានស្រាប់របស់ខ្លួន។

៣. អនុសាសន៍

ដើម្បីកែលម្អការអនុវត្តស្តង់ដានេះឲ្យកាន់តែប្រសើរ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវបំពេញអនុសាសន៍ ដូចខាងក្រោម៖

១. គួរតែបានរៀបចំឱ្យមានរបាយការណ៍ប្រចាំឆ្នាំ២០១២ និង ២០១១ ស្តីពីការវាយតម្លៃការអនុវត្តការងារក្រុមប្រឹក្សាភិបាលរបស់ខ្លួនដែលបានបំពេញការងារកន្លងមក។

២. គួរតែបានបញ្ជាក់ ឬកំណត់ឱ្យបានច្បាស់លាស់ អំពីកាលបរិច្ឆេទ ឈ្មោះហត្ថលេខី ប្រថាប់ត្រា ឬចុះលេខទំព័រ លើឯកសារពាក់ព័ន្ធមួយចំនួនដែលមានស្រាប់ ដើម្បីការដំណើរការការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ស្តង់ដា៣: បុគ្គលិកអប់រំ**

ក្នុងគោលបំណងដើម្បីឲ្យគ្រឹះស្ថានឧត្តមសិក្សាមានគុណភាពអប់រំខ្ពស់ ធានាបាននូវប្រសិទ្ធភាពនៃការផ្ទេរចំណេះដឹង បទពិសោធន៍ និងជំនាញ ដល់និស្សិត គ្រឹះស្ថានឧត្តមសិក្សាត្រូវមានធនធានបុគ្គលិកអប់រំគ្រប់គ្រាន់និងមានគុណភាព ឆ្លើយតបទៅនឹងតម្រូវការក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ការជ្រើសរើស ការអភិវឌ្ឍវិជ្ជាជីវៈដល់បុគ្គលិកអប់រំ និងការទាក់ទាញរក្សាទុកបុគ្គលិកអប់រំដែលមានគុណភាពឲ្យនៅបម្រើការងារក្នុងគ្រឹះស្ថាន គឺជាកត្តាសំខាន់ដែលអាចធ្វើឲ្យសម្រេច គោលបំណងទាំងនេះ។

## ១. ការបំពេញតាមសូចនាករ

### ១.១. គុណវុឌ្ឍិ បទពិសោធន៍ និងការបណ្តុះបណ្តាលរបស់គ្រូបង្រៀនពេញម៉ោងនិង វេលាការ

សាកលវិទ្យាល័យមានធនធានគ្រូបង្រៀនពេញម៉ោង និង វេលាការសមស្របតាមជំនាញ និង កម្រិតបណ្តុះណ្តាលដោយមានឯកសារបញ្ជាក់ពីគុណវុឌ្ឍិនិងបទពិសោធន៍គ្រូបង្រៀនដោយយោង តាម សំណុំឯកសារគ្រូដែលសាកលវិទ្យាល័យបានរក្សាទុកដូចជាជីវប្រវត្តិនិងសញ្ញាបត្រថតចម្លង។ សាកលវិទ្យាល័យមានគ្រូបង្រៀនឯកទេសតាមមហាវិទ្យាល័យនីមួយៗសមស្របតាមជំនាញ និង កម្រិតបណ្តុះណ្តាល ។ គ្រូបង្រៀនមានគុណវុឌ្ឍិ បទពិសោធន៍សមស្របនឹងមុខវិជ្ជាបង្រៀន និង កម្រិតបណ្តុះបណ្តាល។ សាកលវិទ្យាល័យ មានគ្រូបង្រៀនសរុបចំនួន ១៨១នាក់ ក្នុងនោះគ្រូបង្រៀនដែលមាន កម្រិតសញ្ញាបត្របណ្ឌិតចំនួន៧នាក់ត្រូវនឹង៤% មានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ១៧១នាក់ត្រូវនឹង៩៤% និង មានបរិញ្ញាបត្រ ចំនួន ៣នាក់ ត្រូវនឹង២%។

តារាងទី១ ស្ថិតិគ្រូបង្រៀនតាមវិស័យ និងតាមកម្រិតសញ្ញាបត្រ

**តារាងស្ថិតិគ្រូបង្រៀនតាមវិស័យ និងតាមកម្រិតសញ្ញាបត្រ**

| | PhD | Master | Bachelor | Total | %PhD | %Master | %Bachelor | Fulltime | Part-Time |
|---|---|---|---|---|---|---|---|---|---|
| Social Science | 3 | 112 | 1 | 116 | 3 | 97 | 1 | 32 | 84 |
| Language | 1 | 36 | 2 | 39 | 3 | 92 | 5 | 14 | 25 |
| Science and IT | 3 | 23 | | 26 | 12 | 88 | 0 | 8 | 18 |
| Total | 7 | 171 | 3 | 181 | 4 | 94 | 2 | 54នាក់ (30%) | 127នាក់ (70%) |

ប្រភព៖ តារាងស្ថិតិសាស្ត្រាចារ្យរបស់ ស.ភ.ព.អ

### ១.២. គ្រូបង្រៀនពេញម៉ោងមានចំនួនគ្រប់គ្រាន់ ដើម្បីធានាប្រសិទ្ធភាពនៃការបង្រៀន និងណែនាំនិស្សិត

សាកលវិទ្យាល័យមានចំនួនគ្រូបង្រៀនពេញម៉ោងចំនួន៥៤នាក់ ត្រូវនឹង៣០% និងគ្រូបង្រៀនវេលាការចំនួន១២៧នាក់ ត្រូវនឹង៧០%។ សាកលវិទ្យាល័យមានបញ្ជីឈ្មោះមុខវិជ្ជាដែលបង្រៀនដោយគ្រូម្នាក់ៗដោយបែងចែកពេលម៉ោងបង្រៀនរបស់គ្រូបង្រៀនច្បាស់លាស់។ សាកលវិទ្យាល័យបានកំណត់អត្រាផលធៀបគ្រូបង្រៀននឹងនិស្សិតតាមវិស័យនីមួយៗ ក្នុងនោះរួមមានៈ ផលធៀប គ្រូបង្រៀននឹងនិស្សិតសម្រាប់វិស័យវិទ្យាសាស្ត្រសង្គម ១/២៥ វិស័យគណិតវិទ្យា វិទ្យាសាស្ត្រនិងកុំព្យូទ័រ ១/១៨ និងវិស័យភាសាបរទេស ១/២០ (គោលការណ៍ស្តីពីផលធៀបគ្រូបង្រៀននឹងនិស្សិត ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៥)។ ផ្អែកតាមការអនុវត្តជាក់ស្តែង សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានអត្រាផលធៀប គ្រូបង្រៀននឹងនិស្សិតសម្រាប់វិស័យវិទ្យាសាស្ត្រសង្គម ១/១៦ វិស័យគណិតវិទ្យា វិទ្យាសាស្ត្រ និងកុំព្យូទ័រ ១/១៣ និងវិស័យភាសាបរទេស ១/១៤ (ស្ថិតិនិស្សិតនិងស្ថិតិគ្រូរបស់ស.ភ.ព.អ អត្រា ផលធៀបនេះមិនបានរាប់បញ្ចូលទិន្នន័យនិស្សិតក្នុងមជ្ឈមណ្ឌលភាសា និងបណ្តុះបណ្តាល វិជ្ជាជីវៈទេ)។ ផ្អែកតាមអត្រាផលធៀបនេះបញ្ជាក់ថាសាកលវិទ្យាល័យមានធនធានបុគ្គលិកអប់រំគ្រប់គ្រាន់ទាំងគ្រូពេញម៉ោង និង មិនពេញម៉ោងដែលធានាបាននូវភាពគ្រប់គ្រាន់ធនធានបង្រៀន សម្រាប់កម្មវិធីអប់រំរបស់ខ្លួន។

### ១.៣. ដំណើរនៃការជ្រើសរើស អភិវឌ្ឍន៍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកគ្រូ បង្រៀន និងបុគ្គលិក

សាកលវិទ្យាល័យ មានគោលការណ៍ជ្រើសរើសគ្រូច្បាស់លាស់ និង មានគណៈកម្មការជ្រើសរើសគ្រូតាមមហាវិទ្យាល័យនីមួយៗ (គោលការណ៍លេខ ២៥៩/១៣ ស.ភ.ព.អ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣) មុនបញ្ជូនឲ្យគណៈគ្រប់គ្រងពិនិត្យ និងសម្រេចដាក់ស្នើសុំការឯកភាពពីសាកលវិទ្យាធិការ គ្រូបង្រៀនទាំងអស់ដែលត្រូវបានចាត់តាំងឲ្យបង្រៀនតាមឆមាសនីមួយៗដោយមានកិច្ចសន្យាការងារ និង កំណត់លក្ខខណ្ឌការងារសម្រាប់សាស្ត្រាចារ្យដូចមានបញ្ជាក់ក្នុងបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រប់គ្រងគ្រូ និងបុគ្គលិក។

សាកលវិទ្យាល័យបានកំណត់គោលការណ៍លើកទឹកចិត្តផ្តល់រង្វាន់និងផលប្រយោជន៍សម្រាប់គ្រូបង្រៀន និងកំណត់របបអត្រាប្រាក់ម៉ោងបង្រៀនច្បាស់លាស់ (មានបញ្ជាក់ក្នុង បទបញ្ជា ផ្ទៃក្នុងសាស្ត្រាចារ្យ និង គោលការណ៍លេខ ០០៣/០៩ ស.ភ.ព.អ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣)។ ប៉ុន្តែ

តាមរយៈកិច្ចសម្ភាសន៍ជាមួយគ្រូបង្រៀន ការអនុវត្តគោលការណ៍លើកទឹកចិត្ត ផ្ដល់រង្វាន់ និង អត្ថប្រយោជន៍ផ្សេងៗនៅមានកម្រិត។

### ១.៤. ការរក្សាទុកឯកសាររបស់គ្រូបង្រៀនពេញម៉ោង វេលាការ និងបុគ្គលិក

សាកលវិទ្យាល័យ បានរក្សាទុកដាក់ឯកសារពាក់ព័ន្ធនឹងគ្រូបង្រៀនពេញម៉ោង និងមិនពេញម៉ោង ព្រមទាំងបុគ្គលិកបានត្រឹមត្រូវ នៅតាមការិយាល័យព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីមួយៗ។ មានការវាយតម្លៃការងារគ្រូបង្រៀនបានទៀងទាត់ព្រមទាំងបានចងក្រងនិងរក្សាទុកលទ្ធផលវាយ តម្លៃគ្រូ។

សាកលវិទ្យាល័យបានរៀបចំកិច្ចសន្យាបុគ្គលិក និង គ្រូបង្រៀនម្នាក់ៗ ប៉ុន្តែក្នុងកិច្ចសន្យា គ្រូបង្រៀនមួយចំនួន មិនមានបញ្ជាក់ពីអត្រាប្រាក់ម៉ោងបង្រៀន រយៈពេលនៃកិច្ចសន្យា កាលបរិច្ឆេទ ចុះកិច្ចសន្យាជាដើម។

### ១.៥. ការផ្ដល់ប្រាក់បៀវត្ស និង ផលប្រយោជន៍នានាសម្រាប់ទាក់ទាញ និងរក្សាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ឲ្យនៅបម្រើការក្នុងគ្រឹះស្ថាន

សាកលវិទ្យាល័យមានគោលការណ៍ផ្ដល់ប្រាក់បង្រៀនតាមឋានៈរបស់សាស្ត្រាចារ្យ ផ្ដល់លាភការ និងកំណត់របបអត្រាប្រាក់ម៉ោងបង្រៀនច្បាស់លាស់ (បទបញ្ជាផ្ទៃក្នុងសាស្ត្រាចារ្យ និង គោលការណ៍លេខ ០០៣/០៩ ស.ភ.ព.អ)ដែលជាការលើកទឹកចិត្តគ្រូឲ្យនៅបម្រើការនិងចូលរួមសកម្មភាពផ្សេងៗរបស់សាកលវិទ្យាល័យ។

សាកលវិទ្យាល័យ មានកំណត់ត្រាស្ដីពីការផ្លាស់ប្ដូរគ្រូ ដោយមានបញ្ជាក់ពីហេតុផលសមស្រប ដូចជា គ្រូជាប់បំពេញបេសកកម្ម បម្រើការងាររដ្ឋ ផ្លាស់ទីលំនៅជាដើម ប៉ុន្តែសាកលវិទ្យាល័យ មិនមានទិន្នន័យស្ថិតិប្រចាំឆ្នាំស្ដីពីការផ្លាស់ប្ដូរគ្រូបង្រៀន។ ពាក់ព័ន្ធនឹងលក្ខខណ្ឌឬបរិយាកាសការងារ ដែលជាការទាក់ទាញនិងរក្សាទុកគ្រូបង្រៀន ក្រុមមន្ត្រីវាយតម្លៃពិបាកក្នុងការកំណត់ និងសន្និដ្ឋាន ដោយឯកសារកិច្ចសន្យាគ្រូមិនបានបញ្ជាក់ច្បាស់លាស់ពីអត្រាប្រាក់ម៉ោងបង្រៀនរបស់គ្រូ និងត្រូវបានគណៈគ្រប់គ្រងប្រាប់ថាជាការសម្ងាត់។

### ១.៦. កញ្ចប់ថវិកាសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និងបុគ្គលិក

សាកលវិទ្យាល័យមានគោលការណ៍និងផែនការថវិកាសម្រាប់អភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកដែលត្រូវបានលើកសំណើឡើងតាមមហាវិទ្យាល័យ និង ផ្នែកនីមួយៗក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន។

តាមរយៈក្រុមគ្រូបង្រៀនដែលបានផ្តល់បទសម្ភាសន៍ជាមួយក្រុមមន្ត្រីវាយតម្លៃបានបង្ហាញថា កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពជំនាញដល់គ្រូបង្រៀន និង បុគ្គលិកនៅមានកម្រិត។

**១.៧. ការកំណត់ទំហំការងារដល់គ្រូបង្រៀនសមល្មម ស្របតាមការទទួលខុសត្រូវ ក្នុងការបង្រៀន ការផ្តល់ប្រឹក្សា ការស្រាវជ្រាវ និង/ឬ កិច្ចការក្នុងគណៈកម្មការនានា**

សាកលវិទ្យាល័យបានកំណត់ទំហំការងារដល់គ្រូបង្រៀន សមល្មមស្របតាមការទទួលខុសត្រូវ ក្នុងការបង្រៀន ការដឹកនាំធ្វើលំហាត់អនុវត្ត និង ការចូលរួមក្នុងសកម្មភាពសង្គមនានា (មានបញ្ជាក់ក្នុងតារាងមុខវិជ្ជាដែលបង្រៀនដោយគ្រូម្នាក់ៗ និង របាយការណ៍សកម្មភាពផ្សេងៗ)ការបែង ចែកម៉ោងបង្រៀនសម្រាប់គ្រូបង្រៀនម្នាក់ៗមិនលើសពី៣មុខវិជ្ជាដោយមានកិច្ចសន្យា លិខិតបង្គាប់ ការ និង លិខិតតែងតាំង។ សាកលវិទ្យាល័យមានគោលការណ៍ និង នីតិវិធីក្នុងការផ្តល់ប្រឹក្សាដល់ និស្សិតធ្វើឡើងតាមរយៈការិយាល័យប្រឹក្សាយោបល់និស្សិត ដែលបានផ្តល់ប្រឹក្សា និងជួយនិស្សិតលើបញ្ហាជាច្រើនដូចជា និស្សិតរៀនខ្សោយ និស្សិតជួបការលំបាកលើបញ្ហាហិរញ្ញវត្ថុ និង សកម្មភាពជួយរកការងារធ្វើជាដើម។

**១.៨.ការវាយតម្លៃប្រចាំឆ្នាំលើការបំពេញការងាររបស់បុគ្គលិកអប់រំពេញម៉ោង និងវេលាការ ធ្វើឡើង ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ**

សាកលវិទ្យាល័យ បានធ្វើការវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកសិក្សា បានទៀងទាត់តាមឆមាសនីមួយៗ ទាំងគ្រូពេញម៉ោង និង វេលាការ (តាមការសម្ភាសន៍ជាមួយគ្រូ និង និស្សិត និង ឯកសារវាយតម្លៃ)។ សាកលវិទ្យាល័យមានឧបករណ៍វាយតម្លៃបុគ្គលិកអប់រំ បានធ្វើការវាយតម្លៃបុគ្គលិកអប់រំ ព្រមទាំងមានចងក្រងរបាយការណ៍ និងលទ្ធផលនៃការវាយតម្លៃគ្រូបានត្រឹមត្រូវ។

**១.៩. យោបល់កែលម្អពីការវាយតម្លៃត្រូវបានផ្តល់ដល់សាមីខ្លួន និងមានការពិភាក្សារវាងភាគីទាំងសងខាង**

ទោះបីសាកលវិទ្យាល័យបានវាយតម្លៃលទ្ធផលការងាររបស់គ្រូបង្រៀនបានពេញលេញក៏ដោយ ប៉ុន្តែយោបល់កែលម្អពីលទ្ធផលវាយតម្លៃ មិនទាន់បានផ្តល់ដល់សាមីខ្លួន និងមានការពិភាក្សារវាង ភាគីសងខាងឲ្យបានទូលំទូលាយ គឺមិនបានអនុវត្តជាទូទៅគ្រប់ៗគ្រូទេ (ផ្អែកតាមការសម្ភាសន៍ជាមួយគ្រូ)។

### ១.១០. យុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការស្រាវជ្រាវ និងសកម្មភាពសិក្សាស្របតាមបេសកកម្មរបស់គ្រឹះស្ថាន ហើយយុទ្ធសាស្ត្រនេះ អភិវឌ្ឍឡើងដោយមានការចូលរួមពីគ្រូបង្រៀន និងសមាជិកពាក់ព័ន្ធ

សាកលវិទ្យាល័យមានយុទ្ធសាស្ត្រគាំទ្រដល់ការស្រាវជ្រាវ និង សកម្មភាពសិក្សាផ្សេងៗដូចមានបញ្ជាក់ក្នុងផែនការសកម្មភាពតាមមហាវិទ្យាល័យ និង ផ្នែកនីមួយៗ និងបានអនុវត្តគម្រោងថវិកាដែលគាំទ្រដល់សកម្មភាពស្រាវជ្រាវ ថវិកាបដិភាគរបស់សាកលវិទ្យាល័យក្នុងគម្រោងស្រាវជ្រាវដែលឧបត្ថម្ភគាំទ្រដោយធនាគារពិភពលោក។ សាកលវិទ្យាល័យមានក្រុមការងារស្រាវជ្រាវ ដែលបានចងក្រងស្នាដៃស្រាវជ្រាវ អំពីការអភិវឌ្ឍកម្មវិធីសិក្សារបស់ខ្លួន ប៉ុន្តែមិនមានបង្ហាញស្នាដៃស្រាវជ្រាវ ឬបញ្ជីឈ្មោះលទ្ធផលស្រាវជ្រាវដែលបានបោះពុម្ពផ្សេងៗណាទៀតទេ។

### ១.១១. ការណែនាំដល់បុគ្គលិក និងគ្រូបង្រៀនអំពីគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីក្នុងការគាំទ្រដល់ការស្រាវជ្រាវនិងសកម្មភាពសិក្សា

សាកលវិទ្យាល័យមិនបានណែនាំដល់បុគ្គលិក និងគ្រូបង្រៀនឲ្យបានទូលំទូលាយ អំពី គោលនយោបាយ ឬគោលការណ៍ និងនីតិវិធីក្នុងការគាំទ្រដល់ការស្រាវជ្រាវ និងសកម្មភាពសិក្សា នៅឡើយមានគ្រូតិចតួចដែលបានចូលរួមសកម្មភាពស្រាវជ្រាវ(ផ្អែកតាមការធ្វើបទសម្ភាសន៍ជាមួយគ្រូ)។

## ២. សេចក្ដីសន្និដ្ឋាន

តាមការសិក្សាឯកសារ ការពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តជាក់ស្ដែង និង ការធ្វើបទសម្ភាសន៍ជាមួយបុគ្គលិក គ្រូបង្រៀន និងនិស្សិត ព្រមទាំងការវិភាគល្អិតល្អន់ ក្រុមមន្ត្រីវាយតម្លៃយល់ឃើញថា សាកលវិទ្យាល័យបានបំពេញ និង អនុវត្តតាមសូចនាករលម្អិតក្នុងស្តង់ដានេះបានល្អបង្គួរ ដោយ សាកលវិទ្យាល័យ មានបុគ្គលិកអប់រំសមស្របនឹងកម្មវិធីបណ្ដុះបណ្ដាលគ្រូឆ្លងកាត់ការជ្រើសរើសស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ និង ត្រូវបានចាត់តាំងឲ្យបង្រៀន សមនឹងសមត្ថភាព និងកម្រិតទទួលខុសត្រូវលើទំហំការងាររបស់បុគ្គលិកអប់រំ។ សាកលវិទ្យាល័យមានគោលការណ៍ កំណត់ប្រាក់ម៉ោងបង្រៀន និង គោលការណ៍លើកទឹកចិត្តផ្សេងៗអាស្រ័យទៅតាមលទ្ធផលនៃការ បង្រៀន ការចូលរួម និងការលះបង់របស់គ្រូ។ គោលការណ៍នេះជាផ្នែកមួយដើម្បីជាការទាក់ទាញ និងរក្សាធនធានគ្រូបង្រៀន។ យន្តការក្នុងការគ្រប់គ្រងគ្រូ និង ការអភិវឌ្ឍការស្រាវជ្រាវរបស់គ្រូនៅមានកម្រិត ដោយសាកលវិទ្យាល័យមានការខ្វះខាតខ្លះៗដូចជា៖

- ការរៀបចំឯកសារកិច្ចសន្យា តាមបែបបទរដ្ឋបាល ការចងក្រងស្ថិតិប្រចាំឆ្នាំស្ដីពីការផ្លាស់ប្ដូរគ្រូ ការពិភាក្សាពិគ្រោះយល់ ជាមួយគ្រូ ដើម្បីកែលម្អនិងអភិវឌ្ឍគ្រូនៅមានកម្រិត។
- ការផ្ដល់ការណែនាំមិនបានទូលំទូលាយដល់បុគ្គលិកនិងគ្រូបង្រៀនពីគោលការណ៍និងនីតិវិធីដែលគាំទ្រដល់ការស្រាវជ្រាវ ដើម្បីលើក កម្ពស់គុណភាពបណ្ដុះបណ្ដាល និងការស្រាវជ្រាវបង្កើតស្នាដៃ។

៣.អនុសាសន៍

តាមរយៈលទ្ធផលនៃការវាយតម្លៃខាងលើបង្ហាញថា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិនៅមានចំណុចខ្វះខាតមួយចំនួនដែលគួរបំពេញបន្ថែមនិងកែលម្អះ

១.កិច្ចសន្យាគ្រូបង្រៀនគួរមានលក្ខណៈពេញលេញដោយមានការបញ្ជាក់ពីអត្រាប្រាក់ម៉ោងបង្រៀនរយៈពេលនៃកិច្ចសន្យា កាលបរិច្ឆេទចុះកិច្ចសន្យា ឲ្យបានត្រឹមត្រូវតាមបែបបទរដ្ឋបាល។

២.គួររៀបចំស្ថិតិស្ដីពីការផ្លាស់ប្ដូរគ្រូបង្រៀនឲ្យបានច្បាស់លាស់ជាប្រចាំឆ្នាំ។

៣.លទ្ធផលនៃការវាយតម្លៃគ្រូ គួរផ្ដល់ការពិគ្រោះយោបល់ដោយមានការពិភាក្សាទាំសងខាងជាមួយគ្រូបង្រៀនឲ្យបានគ្រប់ៗគ្រូ។

៤.សាកលវិទ្យាល័យ គួរបញ្ជាក់ពីយុទ្ធសាស្ត្រដែលគាំទ្រដល់ការស្រាវជ្រាវឲ្យស្របតាមបេសកកម្មរបស់ខ្លួន និងផ្ដល់ការណែនាំឲ្យបានទូលំទូលាយដល់បុគ្គលិក និងគ្រូបង្រៀនពីគោលការណ៍និង នីតិវិធីដែលគាំទ្រដល់ការស្រាវជ្រាវ ដើម្បីលើកកម្ពស់គុណភាពបណ្ដុះបណ្ដាល និងបង្កើនស្នាដៃស្រាវជ្រាវនិងបោះពុម្ពផ្សាយ។

**ស្ដង់ដា៤៖ កម្មវិធីអប់រំ**

ការសម្រេចបាននិងការរក្សាបាននូវកម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់គឺជាការទទួលខុសត្រូវបឋមរបស់គ្រឹះស្ថានឧត្ដមសិក្សា។ ដោយលក្ខខណ្ឌ និង តម្រូវការតែងតែមានការផ្លាស់ប្ដូរគ្រឹះស្ថានឧត្ដមសិក្សាត្រូវពិនិត្យ វាយតម្លៃនិងកែលម្អកម្មវិធីសិក្សារបស់ខ្លួនក្នុងអំឡុងពេលទៀងទាត់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ តម្រូវការអ្នកសិក្សា និងផ្ដល់គុណភាពនៃចំណេះដឹង បទពិសោធន៍និងជំនាញជាពិសេសកម្មវិធីបណ្ដុះបណ្ដាលត្រូវផ្ដល់នូវលទ្ធផលនៃការសិក្សាដែលបានរំពឹងទុកឆ្លើយតបនឹងកម្រិតគុណវុឌ្ឍិដែលផ្ដល់ឱ្យនិងក្របខណ្ឌគុណវុឌ្ឍិជាតិ។ គ្រឹះស្ថានឧត្ដមសិក្សាមានវិធីសាស្ត្រសមស្របក្នុងការបណ្ដុះបណ្ដាល ការវាយតម្លៃនិស្សិត និង ការរក្សាទុកព័ត៌មានរបស់និស្សិត។ វិធីសាស្ត្រទាំងនេះជាមូលដ្ឋានគ្រឹះក្នុងការធានាគុណភាពនៃកម្មវិធីបណ្ដុះបណ្ដាល។ ដើម្បីសម្រេចបានតាមគោលដៅនៃស្ដង់

ដានេះយើងពិនិត្យឃើញសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបាននិងកំពុងដំណើរការអនុវត្តឲ្យស្របតាមសូចនាករនីមួយៗនៃស្តង់ដា៩ដូចខាងក្រោមៈ

## ១. ការបំពេញតាមសូចនាករ

### ១.១. ការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពរបស់គណៈកម្មាការអភិវឌ្ឍន៍កម្មវិធីសិក្សា

ស.ភ.ព.អ មានគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា និងបានកំណត់តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ដូចមានបញ្ជាក់ក្នុងសេចក្តីសម្រេចលេខ ១៧៣ ស.ភ.ព.អ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៤ និងលិខិតតែងតាំងលេខ ០៦៥ ស.ភ.ព.អ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៥។ គុណវុឌ្ឍិរបស់សមាជិកគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា មានលក្ខណៈសមស្របទៅនឹងការងាររបស់ខ្លួន តាមប្រវត្តិរូបសង្ខេប និង វិញ្ញាបនប័ត្រ ចតចម្លង និងបានកំណត់តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា។ ស.ភ.ព.អ មិនទាន់មានគោលនយោបាយ នីតិវិធី និងលក្ខខណ្ឌសម្រាប់ជ្រើសរើស សមាជិកគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សាទេ។

### ១.២. កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម

ស.ភ.ព.អ បានសិក្សាស្រាវជ្រាវនិងតាមដានលើស្ថានភាពការងាររបស់និស្សិតដែលបានបញ្ចប់ការ សិក្សាសម្រាប់ជំនាន់ទី៧ ទី៨ និង ទី៩ បញ្ជាក់ថានិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើចំនួន ៦៧.៩៤% ដែលបានបង្ហាញនៅក្នុងទិន្នន័យលទ្ធផលស្រាវជ្រាវឆ្នាំ២០១៥។

### ១.៣. មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានប្លង់មេរៀនលំអិតច្បាស់លាស់

គ្រូបង្រៀនម្នាក់ៗបានរៀបចំជាប្លង់មេរៀនតាមមុខវិជ្ជានីមួយៗ ដោយមានបញ្ជាក់ពីឯកសារយោង ការពិពណ៌នាមុខវិជ្ជា វត្ថុបំណង ឯកសារយោង គេហទំព័រ និងសម្ភារៈសិក្សានានា។ ចំណែលលទ្ធផលនៃការសិក្សារបស់និស្សិតតាមក្របខណ្ឌជាតិរៀបចំបានទូលំទូលាយជាបង្គួរអាចទទួលយកបានទេ។

### ១.៤. យន្តការកំណត់ចំនួនក្រេឌីតសិក្សានិងគោលនយោបាយ ឬគោលការណ៍នៃការផ្ទេរ ក្រេឌីត

ស.ភ.ព.អ បានកំណត់ចំនួនក្រេឌីតសិក្សា និង គោលការណ៍ក្នុងការផ្ទេរក្រេឌីតសិក្សាដោយមានគោលការណ៍ផ្ទេរចេញ និង ផ្ទេរចូលព្រមទាំងគោលការណ៍ស្តីពីល័ក្ខខ័ណ្ឌ និង រយៈពេលបញ្ចប់ការសិក្សាតាមកម្រិតកម្មវិធីអប់រំនីមួយៗ តាមបទបញ្ញត្តិសម្រាប់និស្សិតឆ្នាំ២០១៤-២០១៥។

### ១.៥. ការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់និស្សិត

ស.ភ.ព.អបានរៀបចំគ្រប់កម្មវិធីបណ្តុះបណ្តាលមានការពិពណ៌នាអំពីលទ្ធផលសិក្សារបស់និស្សិតដោយបញ្ជាក់ពីចំណេះដឹង ជំនាញ និង/ឬ ឥរិយាបថដែល និស្សិតនឹងទទួលបានតាមលទ្ធផលសិក្សារបស់និស្សិតនៃកម្មវិធីបណ្តុះបណ្តាល ការយកក្របខ័ណ្ឌគុណវុឌ្ឍិជាតិធ្វើជាឯកសាគោលការណ៍ផ្តល់តុល្យភាពសមរម្យរវាងទ្រឹស្តីនិងការអនុវត្តស្របតាមគោលដៅនៃកម្មវិធីបណ្តុះបណ្តាលនិង គ្រឹះស្ថាន

### ១.៦. វិធីសាស្រ្តនិងមធ្យោបាយក្នុងការវាយតម្លៃការសិក្សារបស់និស្សិត

ស.ភ.ព.អ មានគោលការណ៍វាយតម្លៃនិស្សិតតាមវិធីសាស្រ្ត និង មធ្យោបាយច្រើនយ៉ាងដោយផ្តល់ពិន្ទុ ១០% លើវត្តមាន ២០% សម្រាប់ កិច្ចការស្រាវជ្រាវផ្សេងៗ ២៥% សម្រាប់ប្រឡងពាក់កណ្តាល វគ្គ និង ៤៥%លើលទ្ធផលប្រឡងបញ្ចប់ និង បានអនុវត្តទូលំទូលាយ។ លទ្ធផលសិក្សារបស់និស្សិតត្រូវបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេល១សប្តាហ៍បន្ទាប់កាលបរិច្ឆេទប្រឡង ដោយយោងទៅតាមការធ្វើសម្ភាសន៍ ជាមួយនិស្សិត និង សាស្រ្តាចារ្យ និង សៀវភៅបំទបញ្ហាផ្ទៃក្នុងនិស្សិត។

### ១.៧. ពិនិត្យនិងកែលំអរកម្មវិធីអប់រំ

ស.ភ.ព.អ បានសិក្សាពិនិត្យ និង កែលម្អកម្មវិធីបណ្តុះបណ្តាលបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធតាមរបាយការណ៍ពិនិត្យឡើងវិញលើកម្មវិធីសិក្សាដែលមានការចូលរួមពីភាគីពាក់ពន្ធ័ដូចជា និយោជក អតីតនិស្សិត និស្សិតកំពុងសិក្សា និងបុគ្គលិក។

## ២. សេចក្តីសន្និដ្ឋាន

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ជាសាកលវិទ្យាល័យធំមួយក្នុងចំណោមសាកលវិទ្យាល័យធំៗជាច្រើនទៀតនៅប្រទេសកម្ពុជា។ សាកលវិទ្យាល័យ មានធានធានមនុស្ស និង ធនធានសម្ភារគ្រប់គ្រាន់ ដើម្បីកសាងសក្តានុពលក្នុងការទាក់ទាញនិស្សិតឱ្យមកសិក្សាស្រាវជ្រាវនៅសាកលវិទ្យាល័យរបស់ខ្លួន។ នៅក្នុងការរៀបចំកម្មវិធីអប់រំ សាកលវិទ្យាល័យបានបង្កើតគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាដើម្បីរៀបចំកម្មវិធីសិក្សាឱ្យស្របតាមគោលនយោបាយជាតិ រៀបចំគម្រោងលម្អិតមេរៀន ចំនួនក្រេឌីតសិក្សា និង ការផ្ទេរចេញចូល រៀបចំវង្វាយតម្លៃការសិក្សារបស់និស្សិតតាមមធ្យោបាយផ្សេងៗ និងពិនិត្យវាយតម្លៃកម្មវិធីសិក្សាដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ទន្ទឹមនឹងចំណុចល្អទាំងនេះ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលត្រូវកែលម្អដូចជាៈ

– មិនទាន់បានរៀបចំឱ្យមានគោលនយោបាយ ឬ គោលការណ៍ នីតិវិធី និងលក្ខខណ្ឌសម្រាប់ជ្រើសរើសសមាជិកគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា។

– មិនទាន់បានសិក្សានិងឆ្វេងយល់ឲ្យបានទូលំទូលាយអំពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិដែលទើបដាក់ឱ្យដំណើរការនាពេលថ្មីៗកន្លងមក។

ជារួម សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តស្តង់ដាទី៤ ដែលនិយាយអំពីកម្មវិធីអប់រំ និងបានបំពេញសូចនាករព្រមទាំងបានបង្ហាញភស្តុតាងគាំទ្របានល្អ។

## ៣. អនុសាសន៍

ទន្ទឹមនឹងការអនុវត្តបានតាមស្តង់ដា និង បំពេញតាមសូចនាករដូចបានលើកឡើងខាងលើ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិនៅមានចំណុចខ្វះខាត ដែលគួរឬត្រូវបំពេញបន្ថែមក៏ដូចជាកែលម្អ ក្នុងនោះមានៈ

១. គួរកំណត់គោលការណ៍ និង នីតិវិធីក្នុងការជ្រើសរើសគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាឲ្យបានច្បាស់លាស់។

២. គួរបើកវគ្គបណ្តុះបណ្តាលក្របខ័ណ្ឌគុណវឌ្ឍិជាតិ ដល់បុគ្គលិកអប់រំទាំងអស់របស់សាកលវិទ្យាល័យ

## ស្តង់ដា៥៖ សេវានិស្សិត

សេវានិស្សិតជាធាតុមួយដ៏សំខាន់ ក្នុងការចូលរួមចំណែកដល់ការគាំទ្រ ទ្រទ្រង់នៃការអភិវឌ្ឍ និងការពង្រឹង និងពង្រីកសាកលវិទ្យាល័យភ្នំពេញអន្តរជាតិឲ្យរឹងមាំ និងប្រកប ដោយ និរន្តរភាព។ ក្នុងន័យនេះ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានយកចិត្តទុកដាក់ និងឲ្យតម្លៃខ្ពស់ដល់ការផ្តល់សេវានានាដល់និស្សិតដោយបានបង្កើតជាគោលការណ៍ សេចក្តីណែនាំនិងស្ថាប័ននានាដូចជា មជ្ឈមណ្ឌលអភិវឌ្ឍន៍និស្សិត អង្គការនិស្សិត និងការិយាល័យដើម្បីគាំទ្រ និងបម្រើដល់សកម្មភាផ្សេងៗពាក់ព័ន្ធនឹងសេវានិស្សិត។ គោលការណ៍ សេចក្តីណែនាំ និងផ្នែកពាក់ព័ន្ធទាំងអស់ សុទ្ធតែបានបង្កភាពងាយស្រួលមិនត្រឹមតែដល់និស្សិតប៉ុណ្ណោះទេ ថែមទាំងដល់បុគ្គលិក និងសាស្ត្រាចារ្យចំពោះការសិក្សា និងស្រាវជ្រាវ។ ក្រៅពីស្ថាប័នទាំងនេះ មហាវិទ្យាល័យក៏បានដើរតួនាទីដ៏សំខាន់ និងយ៉ាងសកម្មក្នុងការផ្តល់សេវានានា។ មានការលើកទឹកចិត្តដល់និស្សិតជាយន្តការក្នុងការថែរក្សានិស្សិត ក្នុងការជម្រុញឲ្យនិស្សិតខិតខំប្រឹងប្រែ រហូតជោគជ័យបញ្ចប់ការសិក្សា។ ការលើកទឹកចិត្តផ្តល់នូវឱកាសចូលរួមសកម្មភាពបន្ថែមលើការសិក្សា ដូចជា ហាត់ការ ដើម្បីអភិវឌ្ឍអាជីព ជួយស្វែងរកការងារដល់និស្សិត និងការចូលរួមចំណែកក្នុងសកម្មភាពជួយដល់សង្គមដែលជាតម្រូវការចាំបាច់សម្រាប់ជាបទពិសោធន៍ដល់និស្សិត សាកលវិទ្យាល័យ នៅតែបន្តកែលម្អ និងពង្រឹង និងពង្រីកបន្ថែមលើសេវានិស្សិត ដើម្បីឆ្លើយតបទៅនឹង

តម្រូវការ និង ការរីកចម្រើនរបស់ខ្លួនក្នុងពេលបច្ចុប្បន្ន និង អនាគត។ ក្នុងន័យនេះសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តតាមស្តង់ដា និងបានបំពេញនូវសូចនាករដូចខាងក្រោមៈ

## ១. ការបំពេញតាមសូចនាករ

### ១.១. គោលនយោបាយឬគោលការណ៍ ស្តីពីការជ្រើសរើសនិស្សិតចូលរៀនបានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ បានកំណត់គោលនយោបាយស្តីពីការជ្រើសរើសនិស្សិតឲ្យចូលរៀន និង អនុវត្តយ៉ាងច្បាស់លាស់ស្របតាមការណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដោយធ្វើ ឡើងតាមរយៈការប្រកាស និងផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយដល់បេក្ខជន និង សាធារណជនអំពីការចុះឈ្មោះចូលរៀននៅរៀងរាល់វគ្គសិក្សានីមួយៗ។ការចូលរៀនធ្វើឡើងតាមរយៈការប្រឡងដោយមានការត្រួតពិនិត្យពីគណៈកម្មការប្រឡង និង ជ្រើសរើសរបស់ ក្រសួងអប់រំ យុវជន និងកីឡាទៅតាមកម្រិតសិក្សា នីមួយៗ។

### ១.២. អ្នកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិត្រូវមានគុណវុឌ្ឍិនិងបទពិសោធន៍សមស្រប និងកំណត់តួនាទីភារកិច្ចច្បាស់លាស់

សាកលវិទ្យាល័យ មានរចនាសម្ព័ន្ធការិយាល័យជួរមុខអ្នកគ្រប់គ្រង ការិយាល័យសេវានិស្សិតបុគ្គលិកប្រតិបត្តិមានគុណវុឌ្ឍិ និងបទពិសោធសមស្រប ហើយបានអនុវត្តភារកិច្ច តួនាទីតាមការចាត់តាំងដើម្បីបំពេញទៅតាមតម្រូវការជាក់ស្តែងរបស់និស្សិត។ ទន្ទឹមនោះសាកលវិទ្យាល័យមានគោលការណ៍ក្នុងការលើកទឹកចិត្ត និងជម្រុញដល់បុគ្គលិក សាស្ត្រាចារ្យ ក្នុងការអភិវឌ្ឍន៍សមត្ថភាពតាមរយៈការបណ្តុះបណ្តាលបន្ថែម ការចូលរួមក្នុងសិក្ខាសាលាផ្សេងៗ និង តាមរយៈការសិក្សាផ្លាស់ប្តូរបទពិសោធន៍ជាមួយស្ថាប័នដៃគូរទាំងក្នុងស្រុកនិងក្រៅស្រុក។

### ១.៣. គ្រឹះស្ថានឧត្តមសិក្សាផ្តល់សេវាប្រឹក្សា សេវាសុខភាព និង កម្មវិធីអប់រំសុខភាពដល់និស្សិតស្របតាមតម្រូវការជាក់ស្តែង

សាកលវិទ្យាល័យមានសម្ភារៈនិងថ្នាំពេទ្យមួយចំនួនសម្រាប់ជួយសម្រួលដល់និស្សិត បុគ្គលិកសាស្ត្រាចារ្យនៅពេលជួបគ្រោះថ្នាក់ផ្សេងៗក្នុងកម្រិតស្រាលដែលជួយសម្របសម្រួលការិយាល័យ រដ្ឋបាល។ ព្រមជាមួយនោះសាកលវិទ្យាល័យ ក៏បានសហការជាមួយនឹងសមាគមក្នុងស្រុក បង្កើតបរិយាកាសយល់ដឹងបន្ថែមស្តីពី យេនឌ័រ អំពើហឹង្សា និងផ្លូវភេទជាដើម។

**១.៤. គ្រឹះស្ថានឧត្តមសិក្សាមានគោលនយោបាយអាហារូបករណ៍ ដោយមានចែងលក្ខខណ្ឌច្បាស់លាស់ និង អនុវត្តបានត្រឹមត្រូវ**

សាកលវិទ្យាល័យមានគោលការណ៍ និង លក្ខខណ្ឌច្បាស់លាស់ក្នុងការផ្តល់អាហារូបករណ៍ធ្វើឲ្យសាធារណជន និងនិស្សិតជឿជាក់ ដោយមានមានតម្លាភាព មិនលំអៀង និងត្រឹមត្រូវក្នុងការទទួលបានអាហារូបករណ៍ តាមរយៈការប្រឡងជ្រើសរើស។

**១.៥. និស្សិតចូលរៀនថ្មី នៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬ ការតម្រង់ទិសពេញលេញ**

រៀងរាល់មុនពេលវគ្គសិក្សានីមួយៗសាកលវិទ្យាល័យបានប្រជុំតម្រង់ទិសដល់និស្សិតចូលរៀនថ្មីគ្រប់កម្រិតសិក្សាដើម្បីផ្តល់ព័ត៌មានពីការសិក្សា និង នីតិវិធីផ្សេងៗព្រមទាំងជួយប្រឹក្សាយោបល់ទាំងការសិក្សា និង ការបង្កើនសមត្ថភាពដល់និស្សិតឲ្យមានសេចក្តីក្លាហាន ដើម្បីស្នើសុំមតិណែនាំអំពី ការសិក្សារបស់ខ្លួន។

**១.៦. គ្រឹះស្ថានឧត្តមសិក្សាបង្កើត និង ធានាដំណើរការ ប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់**

រៀងរាល់មុនពេលវគ្គសិក្សានីមួយៗសាកលវិទ្យាល័យបានប្រជុំតម្រង់ទិសដល់និស្សិតចូលរៀនថ្មីគ្រប់កម្រិតសិក្សាដើម្បីផ្តល់ព័ត៌មានពីការសិក្សា និង នីតិវិធីផ្សេងៗព្រមទាំងជួយប្រឹក្សាយោបល់ទាំងការសិក្សា និង ការបង្កើនសមត្ថភាពដល់និស្សិតឲ្យមានសេចក្តីក្លាហាន ដើម្បីស្នើសុំមតិណែនាំអំពី ការសិក្សារបស់ខ្លួន។

**១.៧. គ្រឹះស្ថានឧត្តមសិក្សាមានគោលនយោបាយអំពីការផ្ទេរក្រេឌីត និង អនុវត្តបានត្រឹមត្រូវ**

សាកលវិទ្យាល័យបានកំណត់គោលការណ៍ស្តីពីការផ្ទេរក្រេឌីត និង បានអនុវត្តយ៉ាងច្បាស់លាស់ ដើម្បីធានាបាននូវគុណភាព និងរក្សានូវតម្លៃនៃកម្រិតសិក្សាសញ្ញាបត្រនីមួយៗ។

**១.៨. និស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាព បន្ថែមលើការសិក្សា និង កម្មវិធីហ្វឹកហាត់ការងារ**

សាកលវិទ្យាល័យមានកម្មវិធីសិក្សាបន្ថែម និង ការហ្វឹកហាត់ការងារ ហើយមានរបាយការណ៍បញ្ជាក់ពីការពេញចិត្តនិ មិនពេញចិត្តចំពោះកម្មវិធី

**១.៩. គ្រឹះស្ថានឧត្តមសិក្សាជួយនិស្សិតក្នុងការធ្វើផែនការអភិវឌ្ឍន៍អាជីព និង ជួយរកការងារឱ្យនិស្សិត ព្រមទាំងតាមដានអំពីលទ្ធផលការងាររបស់និស្សិត**

សាកលវិទ្យាល័យបានលើកទឹកចិត្តផ្តល់នូវឱកាសចូលរួមសកម្មភាពបន្ថែមលើការសិក្សា ដូចជាហាត់ការដើម្បីអភិវឌ្ឍអាជីព ជួយស្វែងរកការងារដល់និស្សិត និងការចូលរួមចំណែកក្នុងសកម្មភាពជួយដល់សង្គមដែលជាតម្រូវការចាំបាច់ សម្រាប់ជាបទពិសោធន៍ដល់និស្សិត។ មានការលើកទឹក ចិត្តដល់និស្សិតជាយន្តការក្នុងការថែរក្សានិស្សិត ក្នុងការជម្រុញឲ្យនិស្សិតខិតខំប្រឹងប្រែរហូតជោគជ័យបញ្ចប់ការសិក្សា។

**១.១០. គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើការស្រាវជ្រាវអំពី លទ្ធផល និង ភាពជោគជ័យក្នុងការទទួលបានការងារធ្វើរបស់និស្សិត ដែលបានបញ្ចប់ការសិក្សា**

បានរៀបចំរបាយការណ៍ស្តីពីការស្រាវជ្រាវពីលទ្ធផលនិងភាពជោគជ័យក្នុងការទទួលបានការងាររបស់និស្សិត។

**១.១១. និស្សិតទទួលបានឱកាសចូលរួមក្នុងសេវាជួយសហគមន៍ និង សកម្មភាពជួយសង្គម ផ្សេងៗ**

សាកលវិទ្យាល័យបានជម្រុញ និង ផ្តល់ឱកាសពិតប្រាកដឲ្យនិស្សិតបានចូលរួមប្រកួតប្រជែងពីក្នុងស្រុករហូតដល់ថ្នាក់អន្តរជាតិ និង ទទួលបានចំណាត់ថ្នាក់ដ៏ប្រសើរផងដែរ។ សាកលវិទ្យាល័យបានលើកទឹកចិត្តដល់និស្សិតឲ្យចូលរួមសកម្មភាពសង្គមជាមួយដៃគូពាក់ព័ន្ធទាំងនៅក្នុងនិងក្រៅសាកលវិទ្យាល័យ ដើម្បីផ្សព្វផ្សាយ លើកកម្ពស់សីលធម៌ មនុស្សធម៌ សប្បុរសធម៌ និងចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ។

**១.១២. គ្រឹះស្ថានឧត្តមសិក្សាមានគោលនយោបាយ និង នីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយរាល់ បណ្តឹងតវ៉ារបស់និស្សិត**

សាកលវិទ្យាល័យបានដោះស្រាយបណ្តឹងតវ៉ារបស់និស្សិត ទៅតាមករណីដោយឡែកនីមួយៗ ប៉ុន្តែពុំមានគោលការណ៍ស្តីពីបណ្តឹងតវ៉ា និងនីតិវិធីដាក់ពិន័យ។

**១.១៣. គ្រឹះស្ថានឧត្តមសិក្សាមានគោលនយោបាយឬគោលការណ៍ស្តីពីភាពជោគជ័យក្នុងការសិក្សាការថែរក្សានិស្សិតនិងអត្រាបញ្ចប់ការសិក្សា**

សាកលវិទ្យាល័យមានបទបញ្ញត្តិសម្រាប់និស្សិត និង មានគោលការណ៍សម្រាប់ជ្រើសរើសនិស្សិតពូកែប្រចាំឆ្នាំសិក្សាដើម្បីជម្រុញ និងលើកទឹកចិត្តដល់ការសិក្សារបស់និស្សិតទៅកម្រិតជំនាញ។

ជារៀងរាល់ឆ្នាំ សាកលវិទ្យាល័យតែងតែធ្វើការស្រាវជ្រាវចងក្រងនូវព័ត៌មានទាក់ទងនឹងការទទួលបានការងារធ្វើរបស់និស្សិត បន្ទាប់ពីការបញ្ចប់ការសិក្សា។

## ២. សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបានតាមគោលដៅនៃស្តង់ដានេះ សាកលវិទ្យាល័យបានផ្តល់សេវានិស្សិត និងការចូលរួមសហគមន៍ពីសំណាក់និស្សិតជាច្រើនសកម្មភាព។ ក្រៅពីការសិក្សាតាមកម្មវិធីអប់រំសកម្មភាពទាំងក្នុងនិងក្រៅសាកលវិទ្យាល័យត្រូវបានផ្តល់ដល់និស្សិតសម្រាប់សិក្សាបន្ថែមនិងដកស្រង់យកបទពិសោធន៍ពីការចូលជាសមាជិកក្នុងក្លិបពិភាក្សាក្រុមយុវជនកាកបាទក្រហមជាដើម។ សាកលវិទ្យាល័យភ្នំពេញបានរៀបចំផ្តល់នូវកម្មវិធីហ្វឹកហាត់ការងារដល់និស្សិតនៅមហាវិទ្យាល័យ និង ផ្នែកជំនាញនានា សំដៅរួមចំណែកបណ្តុះបណ្តាលនិស្សិតឲ្យក្លាយទៅជាធនធានមួយដែលមានគុណភាព និងប្រសិទ្ធភាពបំពេញការងារទៅអនាគត។ ធ្វើដូច្នេះដើម្បីជួយឲ្យនិស្សិតក្លាយជានិស្សិតឆ្នើមនិងជាពលរដ្ឋល្អក្នុងសង្គមស្របតាមទិសដៅរបស់សាកលវិទ្យាល័យ។ ទន្ទឹមនឹងការមានចំណុចល្អប្រសើរជាច្រើននោះ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិក៏នៅមានចំណុចខ្វះខាតដោយពុំទាន់បានរៀបចំគោលការណ៍ស្តីពីបណ្តឹងតវ៉ា និងនីតិវិធីដាក់ពិន័យឲ្យបានច្បាស់លាស់ដើម្បីជាយន្តការក្នុងការអនុវត្ត។ ជារួមមកសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ បានអនុវត្តស្តង់ដា៥លើការងារសេវានិស្សិតដោយបានបំពេញសូចនាករភាគច្រើន ព្រមទាំងបានបង្ហាញភស្តុតាងគាំទ្របានល្អ។

## ៣. អនុសាសន៍

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ បានដាក់ចេញនូវគោលនយោបាយ នឹងលក្ខខណ្ឌមានលក្ខណៈល្អប្រសើរ ជាធាតុក្នុងការផ្តល់នូវការយកចិត្តទុកដាក់សម្រាប់ការសម្រួល ដល់ការសិក្សារបស់និស្សិត ដើម្បីឆ្លើយតប និង តម្រូវការសេវារបស់និស្សិតទូទៅ ក៏ប៉ុន្តែនៅមានចន្លោះខ្លះដូចជា៖

១.គួរពិនិត្យ និង កែលម្អលើការរៀបចំដាក់ចេញគោលនយោបាយស្តីពីបណ្តឹងតវ៉ា និង នីតិវិធីដាក់ពិន័យលើការប្រព្រឹត្តល្មើសវិន័យនិស្សិត។

## ស្តង់ដា៦៖ ធនធានសិក្សា

ដើម្បីគាំទ្រដល់ការបង្រៀន ការសិក្សា និង ការស្រាវជ្រាវ ស្របតាមបេសកកម្ម និង គោលដៅនៃការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន ធនធានសិក្សា បណ្ណាល័យ បន្ទប់ពិសោធន៍ សៀវភៅសិក្សា និងអ៊ីនធឺណិត គឺជាតម្រូវការចាំបាច់និងត្រូវមានចំនួនសមស្របទៅនឹងកម្មវិធីអប់រំ។ គ្រឹះស្ថានឧត្តមសិក្សា

ត្រូវយកចិត្តទុកដាក់អភិវឌ្ឍធនធានសិក្សាឲ្យមានលក្ខណៈគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាពដើម្បីគាំទ្រដល់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវ របស់គ្រូបង្រៀន និងនិស្សិត។

ដើម្បីសម្រេចបានតាមគោលដៅខាងលើសាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិបានបំពេញនូវ សូចនាករនៃស្តង់ដា៦ដូចខាងក្រោមៈ

១. ការបំពេញតាមសូចនាករ

១.១. បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និង បរិយាកាសអំណោយផលដល់ការសិក្សា និង ការស្រាវជ្រាវ

សាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ មានបណ្ណាល័យមួយ ដែលមានសម្ភាររូបវន្ត និងផ្តល់សេវាដល់និស្សិតនិងមានបណ្ណារក្សដែលបានជ្រើសរើសនិងធ្វើការបណ្តុះបណ្តាលពីបច្ចេកទេសបណ្ណាល័យព្រមទាំងបានកំណត់ទំហំការងារ និងការទទួលខុសត្រូវច្បាស់លាស់។

១.២. បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និង សម្ភារសិក្សាផ្សេងៗ សម្រាប់គាំទ្រដល់កម្មវិធីអប់រំ

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានរៀបចំបញ្ជីសៀវភៅដែលមានក្នុងបណ្ណាល័យនិងបានបញ្ចូលទិន្នន័យសៀវភៅទាំងនោះក្នុងប្រព័ន្ធកុំព្យូទ័រ។ សំរាប់សៀវភៅសិក្សាគឺមានសមល្មម ប៉ុន្តែឯកសារយោង ទស្សនាវដ្តី និងសម្ភារសិក្សាផ្សេងទៀតដែលគាំទ្រដល់កម្មវិធីអប់រំគឺនៅមានកម្រិត។

១.៣. បណ្ណាល័យមានបណ្ណារក្ស និង បុគ្គលិកបម្រើការគ្រប់គ្រាន់ និងទទួលបានការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់និស្សិត និងគ្រូបង្រៀន

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានបណ្ណារក្សនិងអ្នកគ្រប់គ្រងបណ្ណាល័យដែលបានជ្រើសតាំងនិងធ្វើការបណ្តុះបណ្តាលពីបច្ចេកទេសបណ្ណាល័យព្រមទាំងបានកំណត់ទំហំការងារនិងការទទួលខុសត្រូវច្បាស់លាស់(បញ្ជាក់ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងបណ្ណាល័យនិងក្នុងលិខិតតែងតាំង)។

១.៤. ចំនួនម៉ោងបើកបម្រើសេវារបស់បណ្ណាល័យស្របទៅនឹង តម្រូវការរបស់និស្សិត និង គ្រូបង្រៀន

ម៉ោងបម្រើសេវាបណ្ណាល័យសមស្របតាមពេលម៉ោង និង វគ្គសិក្សា ថ្ងៃច័ន្ទ-សៅរ៍ ចាប់ពីម៉ោង ៧.០០ ដល់ម៉ោង១១.៣០ និង១៤.០០ដល់ ២០.៣០នាទីយប់។

**១.៥. និស្សិត និងគ្រូបង្រៀនទទួលបានការណែនាំនិងតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។**

សាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិមានកម្មវិធីណែនាំការប្រើប្រាស់បណ្ណាល័យ (លិខិតលេខ ០៣៩/១៥ ស.ភ.ព.អ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៥)។

**១.៦. និស្សិត និងគ្រូបង្រៀនទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិត សម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវ ស្របតាមកម្មវិធីអប់រំ**

បណ្ណាល័យបានរៀបចំប្រព័ន្ធពត៌មានវិទ្យានៅក្នុងបណ្ណាល័យដែរ តែធនធានសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចនៅមានកម្រិត ដោយបណ្ណាល័យមិនទាន់មាន ធនធានសិក្សាផ្ទាល់ខ្លួន ដែលអាចបញ្ចូលក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិតនៅឡើយទេ។

**១.៧. បណ្ណាល័យមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រផែនការ រយៈពេលវែង និង រយៈពេលខ្លី ដើម្បីអភិវឌ្ឍន៍បណ្ណាល័យឱ្យកាន់តែប្រសើរឡើង**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិកំពុងអភិវឌ្ឍបណ្ណាល័យធំទូលាយនៅជាន់ទី៧មានស្តង់ដា សម្រាប់តម្រូវការនៃការប្រើប្រាស់នាថ្ងៃអនាគតដោយប្រើប្រាស់ថវិកាការអភិវឌ្ឍក្រោមគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន JCMK Group។

**១.៨. គ្រឹះស្ថានឧត្តមសិក្សាមានបន្ទប់ពិសោធន៍ទូទៅ និងឯកទេស ប្រដាប់ដោយបរិក្ខារពេញលេញ សម្រាប់គាំទ្រដល់ការបង្រៀន ការសិក្សា និង ការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ**

យោងតាមការពិនិត្យជាក់ស្តែងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានបន្ទប់ពិសោធន៍ចំនួន៣ ដែលបន្ទប់ចំនួន២ប្រើសំរាប់ IT Labs និង មួយបន្ទប់ទៀតប្រើសំរាប់ Language Labs។ បន្ទប់ពិសោធន៍នីមួយៗមាន បញ្ជីសារពើភណ្ឌ និងបញ្ជីសម្ភារៈដែលបំពាក់ តែមិនទាន់ទូលំទូលាយដើម្បីងាយស្រួលក្នុងការតាមដាននិងត្រួតពិនិត្យដល់ដំណើរការពិសោធន៍របស់និស្សិតនៅឡើយទេ។ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រើប្រាស់បន្ទប់ពិសោធន៍នីមួយៗ។

**១.៩. គ្រឹះស្ថានឧត្តមសិក្សាមានផែនការអភិវឌ្ឍ បន្ទប់ពិសោធន៍ រយៈពេលវែង និង រយៈពេលខ្លី**

សាកលវិទ្យាល័យមិនមានបញ្ជាក់ពីផែនការអភិវឌ្ឍបន្ទប់ពិសោធន៍សម្រាប់រយៈពេលវែងក្នុងក្របខណ្ឌសាកលវិទ្យាល័យផ្ទាល់ទេ ប៉ុន្តែមានផែនការអភិវឌ្ឍក្រោមគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន JCMK Group។

**១.១០. គ្រឹះស្ថានឧត្តមសិក្សាមានបុគ្គលិកដែលបានឆ្លងកាត់ការ បណ្តុះបណ្តាលត្រឹមត្រូវ និងមានចំនួនគ្រប់គ្រាន់សម្រាប់ បម្រើតម្រូវការ និងដំណើរការរបស់បន្ទប់ពិសោធន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងការសិក្សា**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានបុគ្គលិគជំនួយការ និង មន្ត្រីបម្រើការបន្ទប់ពិសោធន៍ដែលឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវសម្រាប់បម្រើតម្រូវការនិងដំណើរការរបស់ បន្ទប់ពិសោធន៍។

**១.១១. គ្រឹះស្ថានឧត្តមសិក្សាមានគោលនយោបាយ ឬគោលការណ៍ អំពីសុវត្ថិភាព និង អនុវត្តប្រកបដោយប្រសិទ្ធភាព**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានគោលការណ៍ស្តីពីសុវត្ថិភាព មានក្រុមសន្តិសុខបម្រើការ និងមានច្រកចេញចូលសុវត្ថិភាព ដោយមានការយាមកាម។

**១.១២. គ្រឹះស្ថានឧត្តមសិក្សាមានធនធានបច្ចេកវិទ្យា និង អ៊ីនធឺណិតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សា ដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេស ដើម្បីបំពេញតម្រូវការតាមកម្មវិធីអប់រំ**

សាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិមានធនធានបច្ចេកវិទ្យា កុំព្យូទ័រ និង អ៊ីនធឺណែតសម្រាប់គាំទ្រការសិក្សា និង បម្រើតម្រូវការទូទៅ និង មុខវិជ្ជាឯកទេស តាមកម្មវិធីអប់រំរបស់ខ្លួន តែធនធានសិក្សាទាំងនោះនៅមានកំរិត។

**១.១៣. គ្រឹះស្ថានឧត្តមសិក្សាផ្តល់វគ្គបណ្តុះបណ្តាលសមស្របអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា ដែលមានក្នុងគ្រឹះស្ថានដល់គ្រូបង្រៀន បុគ្គលិក និងនិស្សិត**

សាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិមិនមានបញ្ជាក់ពីកម្មវិធី និងរបាយការណ៍បណ្តុះបណ្តាលគ្រូបុគ្គលិក និងនិស្សិត អំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មានផ្សេងៗដែលខ្លួនមាន ឲ្យបានទូលំទូលាយនៅឡើយ មានតែការបណ្តុះបណ្តាលខ្លះៗ។

**១.១៤. គ្រឹះស្ថានឧត្តមសិក្សាមានបុគ្គលិក ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់ សម្រាប់គាំទ្រ និង ជួយសម្រួលផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានការិយាល័យថែទាំ និង ជួសជុលដែលមានបុគ្គលិកសម្រាប់ជួយសម្រួលបញ្ហាបច្ចេកទេសដែលកើតមានឡើងនៅតាមបន្ទប់សិក្សា និងបន្ទប់ពិសោធន៍។

## ២. សេចក្តីសន្និដ្ឋាន

ថ្វីត្បិតតែសាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានបណ្ណាល័យបច្ចុប្បន្នតូចបន្តិចប៉ុន្តែមានកន្លែងអានសមស្របសម្រាប់និស្សិតស្រាវជ្រាវ។ បុគ្គលិកបណ្ណាល័យមានកាបណ្តុះបណ្តាលនិងមានការបែង

ចែកតួនាទីភារកិច្ចច្បាស់លាស់ ព្រមទាំងមានគោលការណ៍ច្បាស់លាស់ក្នុងការគ្រប់គ្រងបណ្ណាល័យ។ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានធ្វើការណែនាំដល់គ្រូ និង និស្សិត ក្នុងការប្រើប្រាស់បណ្ណាល័យបានមួយចំនួន។ ទោះជាយ៉ាងណាបណ្ណាល័យកំពុងដំណើរបច្ចុប្បន្នរបស់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិនៅមានចំណុចខ្វះខាតមួយចំនួនដូចជា៖

- បណ្ណាល័យបច្ចុប្បន្នមិនទាន់មានគ្រប់គ្រាន់នូវ ឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រនិងសម្ភារៈសិក្សាផ្សេងៗ សម្រាប់គាំទ្រដល់កម្មវិធីអប់រំ។
- ធនធានសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ក្នុងបណ្ណាល័យទូរនិម្មិតនៅមិនទាន់រំលេចច្បាស់លាស់។
- សាកលវិទ្យាល័យមិនមានបញ្ជាក់ពីផែនការអភិវឌ្ឍបណ្ណាល័យសម្រាប់រយៈពេលវែងក្នុងក្របខណ្ឌសាកលវិទ្យាល័យផ្ទាល់ទេ ប៉ុន្តែមានផែនការអភិវឌ្ឍបណ្ណាល័យក្រោមគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន JCMK Group។

ការវាយតម្លៃជារួមសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តតាមស្តង់ដាស្តីពីធនធានសិក្សានិងបំពេញសូចនាករក្នុងស្តង់ដា៦នេះបានល្អ។

៣. អនុសាសន៍

ទន្ទឹមនឹងអនុវត្តបានតាមស្តង់ដា និងបំពេញតាមសូចនាករដូចបានលើកឡើងខាងលើសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅមានចំណុចខ្វះខាតមួយចំនួនដែលគួរ ឬ ត្រូវបំពេញបន្ថែមក្នុងនោះរួមមាន៖

១.គួរបន្ថែមឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗ សម្រាប់គាំទ្រដល់កម្មវិធីអប់រំ
២.គួរបន្ថែមធនធានសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចអោយបានច្រើន
៣.គួរបង្កើតធនធានសិក្សាក្នុងបណ្ណាល័យទូរនិម្មិតឲ្យបានទូលំទូលាយ
៤.គួរបង្កើនវិសាលភាព Internet ដើម្បីសម្រួលដល់ការប្រើប្រាស់របស់និស្សិត
៥.គួរមានប្រព័ន្ធសុវត្ថិភាពក្នុងបណ្ណាល័យនិងគួរមានបន្ទប់ពិភាក្សាជាក្រុមនៅជ្រុងណាមួយនៃបណ្ណាល័យបច្ចុប្បន្នដើម្បីកុំឲ្យរំខានដល់អ្នកអានផ្សេងទៀត

**ស្តង់ដា៧៖ ធនធានរូបវន្ត**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានទីតាំងប្រកបដោយបរិស្ថានល្អ ដែលអំណោយផលដល់ការបង្រៀន និងការសិក្សា និងមានទីធ្លាធំទូលាយសម្រាប់សកម្មភាពកីឡា សិល្បៈ និងសកម្មភាពផ្សេងៗទៀត។ គ្រឹះស្ថានឧត្តមសិក្សា មានអគារសិក្សា បន្ទប់សិក្សា ការិយាល័យ បន្ទប់ប្រជុំ សាលសហសិក្សា និងការផ្គត់

ផ្តល់អគ្គីសនី និងទឹកគ្រប់គ្រាន់ ហើយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។

## ១. ការបំពេញតាមសូចនាករ

### ១.១. គ្រឹះស្ថានឧត្តមសិក្សាមានធនធានរូបវន្តគ្រប់គ្រាន់ សម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ រួមទាំងសកម្មភាពសិក្សា និងសកម្មភាពបន្ថែមលើការសិក្សារបស់និស្សិត ដែលកំពុងសិក្សាបច្ចុប្បន្ន និងអនាគត

សាកលវិទ្យាល័យបានវិនិយោគលើធនធានរូបវន្តដើម្បីបំពេញសកម្មភាពសិក្សានិងសកម្មភាពផ្សេងៗដូចបង្ហាញក្នុងតារាងខាងក្រោមៈ

តារាងទី ២ បង្ហាញពីស្ថិតិបន្ទប់ប្រជុំ និងបន្ទប់ការិយាល័យ

| ល.រ | បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | បន្ទប់ការិយាល័យ | ១៥ | ជាន់ទី៥ |
| ២ | បន្ទប់ញ៉ាំអាហារ | ១ | ជាន់ទី៥ |
| ៣ | បន្ទប់ឃ្លាំង | ១ | ជាន់ទី៥ |
| ៤ | បន្ទប់ទំនេរ | ៣ | ជាន់ទី៥ |
| ៥ | បន្ទប់អនុវត្តកុំព្យូទ័រ | ២ | ជាន់ទី៥ |
| ៦ | បន្ទប់ប្រជុំ | ១ | ជាន់ទី៥ |
| ៧ | សាលប្រជុំជាន់ទី៥ | ១ | ផ្ទុកមនុស្សបាន១៥០នាក់ |
| ៨ | សាលប្រជុំជាន់ទី៧ | ១ | ផ្ទុកមនុស្សបាន៣៥០នាក់ |
| ៩ | សាលប្រជុំជាន់ទី១២ | ១ | ផ្ទុកមនុស្សបាន៣៥០នាក់ |
| ១០ | បន្ទប់សិក្សា | ៨៩ | ជាន់ទី៣ ទី៤ និងទី៦ |
| ១១ | បន្ទប់អនុវត្តភាសា | ២ | ជាន់ទី១ និងទី៧ |
| ១២ | បណ្ណាល័យ | ១ | ជាន់ឡៅតឿ និងប្តូរទៅជាន់ទី៧ ដើមឆ្នាំ២០១៦ |

តារាងទី៣ បង្ហាញពីស្ថិតិសម្ភារៈរូបវន្ត

| ល.រ | បរិយាយ | ចំនួន | ចំនួនត្រៀមឆ្នាំសិក្សា ២០១៦-២០១៧ (ថែម១០បន្ទប់) | ផ្សេងៗ |
| --- | --- | --- | --- | --- |
| ១ | ម៉ាស៊ីនត្រជាក់ | ១៨៣ | ៣០ | ដាក់តាមបន្ទប់ |
| ២ | កង្ហារ | ១២២ | ២០ | ដាក់តាមបន្ទប់ |
| ៣ | អំពូលភ្លើងម៉ែត្រ | ១៥៩៦ | ៣៦០ | ដាក់តាមបន្ទប់ |
| ៤ | អំពូលអ៊ុយ | ២៦៩ | ១០ | តាមផ្លូវ និង បន្ទប់ទឹក |
| ៥ | តុគ្រូ | ៥២ | ១០ | តាមបន្ទប់ |
| ៦ | កៅអីគ្រូ | ៥២ | ១០ | តាមបន្ទប់ |
| ៧ | តុនិស្សិត | ៨៧៩ | ៣០០ | តាមបន្ទប់ |
| ៨ | កៅអីនិស្សិត | ២៤៥០ | ៦០០ | តាមបន្ទប់ |
| ៩ | កៅអីសម្រាប់រៀបចំកម្មវិធី | ៧១៩ | ១០០ | ក្នុងឃ្លាំង |
| ១០ | ក្ដាខៀន | ៥២ | ១០ | តាមបន្ទប់ |
| ១១ | LCD Projector | ១៣ | ៣៩ | ចល័ត |
| ១២ | កុំព្យូទ័រ | ៧៦ | | បន្ទប់lab |
| ១៣ | បំពង់ពន្លត់អគ្គីភ័យBC | ០២ | | |
| ១៤ | បំពង់ពន្លត់អគ្គីភ័យABC | ៤៧ | | |
| ១៥ | ភួយពន្លត់អគ្គីភ័យ | ០១ | | |

## ១.២. គ្រឹះស្ថានឧត្តមសិក្សាមានបរិស្ថានប្រកបដោយជាសុកភាព និងសុវត្ថិភាពដែល បំពេញតាមលក្ខខណ្ឌស្តីពីសុវត្ថិភាព

បន្ទប់សិក្សានៅសាកលវិទ្យាល័យមានលក្ខណៈធំទូលាយ បានបង្កបរិយាកាសរៀនសូត្រយ៉ាងប្រសើរទៅតាមភាពបត់បែននៃវិធីសាស្ត្របង្រៀនដោយរក្សាបាននូវភាពស្ងប់ស្ងាត់ ខ្យល់ ពន្លឺចូលគ្រប់គ្រាន់និងបំពាក់ម៉ាស៊ីនត្រជាក់តាមបន្ទប់។ គ្រឿងបរិក្ខារជាច្រើននៅក្នុងថ្នាក់រៀនត្រូវបានបំពាក់ ដែលមានដូចជាកៅអីថ្នាក់ដែលសម្រាប់និស្សិតម្នាក់ៗ តុនិងកៅអីគ្រូ ក្តារខៀន រូបភាពនានា ឧបករណ៍បញ្ចាំងស្លាយ ដែលសំដៅដល់សម្ភារៈឧបទ្ទេសន៍ សម្រាប់ដំណើរការ បង្រៀននិងរៀន។

## ១.៣. បទបញ្ញានិង/ឬសេចក្តីណែនាំ ស្តីពី សុខភាព សុវត្ថិភាព សន្តិសុខ ត្រូវបានផ្សព្វផ្សាយ អនុវត្តនិងវាយតម្លៃជាប្រចាំ

សាកលវិទ្យាល័យមានបទបញ្ញា សេចក្តីណែនាំស្តីពី សុខភាព សុវត្ថិភាព និងសន្តិសុខ មានសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបន្ទប់អនុវត្តកុំព្យូទ័រ ព្រមទាំងមានការផ្សព្វផ្សាយស្តីពីការប្រើប្រាស់ឧបករណ៍ក្នុងករណីមានគ្រោះអាសន្ន ការដាក់ស្លាកទីតាំងសម្គាល់ក្នុងករណីមានគ្រោះអាសន្នក្នុងទីធ្លាសាកលវិទ្យាល័យ និង បានបិទផ្សាយជូនដំណឹងដល់និស្សិត បុគ្គលិក សាស្ត្រាចារ្យ និងគ្រប់ផ្នែកពាក់ព័ន្ធ។

## ១.៤. ការគ្រឹះស្ថានឧត្តមសិក្សាមានការសាកល្បង ជម្លៀសបន្ទាន់ជាក់ស្តែង ដើម្បីដោះស្រាយគ្រោះមានអាសន្នផ្សេងៗ

ដោយប្លង់អាគារសាកលវិទ្យាល័យបិតក្រោមការសាងសង់ នោះការសាកល្បង ជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រោះមានអាសន្នផ្សេងៗ សាកលវិទ្យាល័យគ្រោងរៀបចំធ្វើនៅក្រោយពេលដែលការសាងសង់ត្រូវបានបញ្ចប់។

## ១.៥. គ្រឹះស្ថានឧត្តមសិក្សា មានគោលនយោបាយ ឬគោលការណ៍ សុវត្ថិភាព ស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធព័ត៌មានអេឡិចត្រូនិចផ្លូវការរួមទាំងឃ្លាំងការពារអគ្គីភ័យ និងការថតចម្លងទុក

នៅក្នុងដំណើរការនៃការគ្រប់គ្រងគ្រឹះស្ថាន ប្រព័ន្ធទិន្នន័យត្រូវបានប្រើប្រាស់ដោយភាគីពាក់ព័ន្ធ ដើម្បីអោយទទួលបានប្រសិទ្ធភាពទាំងការបំពេញ ការងារ ឆ្លើយតបតម្រូវការ ដំណើរការស្ថាប័ន និងគាំទ្រដល់វិធីសាស្ត្របង្រៀនជាដើម។ការគ្រប់គ្រងប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យានៅសាកលវិទ្យាល័យ

ភ្នំពេញត្រូវបានរៀបចំ ឡើងដើម្បីគ្រប់គ្រងព័ត៌មានទាក់ទងនឹងការសិក្សាគ្រប់កម្រិត។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យគឺពាក់ព័ន្ធទៅនឹងការប្រមូលទិន្នន័យ ការផ្ទុកនិងរក្សាទុកព័ត៌មាន ការរៀបចំកាលវិភាគ និងរបាយការណ៍ព័ត៌មាន គ្រឹះស្ថានស្ថិតិនិស្សិត គុណវុឌ្ឍិគ្រូ និងស្ថិតិបុគ្គលិក។

## ១.៦. គ្រឹះស្ថានឧត្តមសិក្សាមានអភិវឌ្ឍន៍ធនធានរូបវន្ត រយៈពេលវែង រយៈពេលខ្លី និងបានអនុវត្ត

ផែនការអភិវឌ្ឍន៍និងពង្រីកបន្ថែមនូវអគារសាកលវិទ្យាល័យតាមរយៈការសាងសង់បណ្ណាល័យនិងបន្ទប់សិក្សាបន្ថែម សម្រាប់ជាមូលដ្ឋានគាំទ្រការសិក្សា ការបង្រៀន ស្រាវជ្រាវ និងការវិវត្តសាកលវិទ្យាល័យ។ ផែនការអភិវឌ្ឍបណ្ណាល័យសម្រាប់រយៈពេលវែង របស់សាកលវិទ្យាល័យ គឺមានភ្ជាប់ជាមួយគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន JCMK Group ខណៈដែលប្រតិបត្តិការរបស់សាកលវិទ្យាល័យជាឧបសម្ព័ន្ធរបស់ក្រុមហ៊ុន JCMK Group ព្រមជាមួយគ្នានោះក្រោយពេលបញ្ចប់ការសាងសង់ ក្រុមហ៊ុននឹងកាត់ឲ្យនៅក្រោមប្រតិបត្តិការរបស់សាកលវិទ្យាល័យវិញ។

## ២. សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបានតាមគោលដៅនៃស្តង់ដានេះ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានបំពេញតាមនូវសូចនាករដោយមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានទីតាំងផ្ទាល់ខ្លួននិងការបំពាក់សម្ភារបន្ថែមរួមបញ្ចូលទាំងបន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់សិក្សា ការិយាល័យ បន្ទប់ប្រជុំ សាលប្រជុំ ការផ្គត់ផ្គង់អគ្គីសនី និងទឹកប្រើប្រាស់គ្រប់គ្រាន់ ហើយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ជារួមសាកលវិទ្យាល័យភ្នំពេញអន្តរជាតិមានធនធានរូបវន្តពេញលេញដូចជាអគារសិក្សាផ្ទាល់ខ្លួនអាហារដ្ឋានឧបករណ៍សុវត្ថិភាព និងថ្នាក់រៀន។ ផែនការមេជាច្រើនដែលមានគម្រោងសាងសង់បន្ថែម ក្នុងនោះដូចជាមានផែនការអភិវឌ្ឍន៍បណ្ណាល័យនៅជាន់ទី៧ជាដើម។ ទន្ទឹមនឹងចំណុចល្អប្រសើរជាច្រើននោះសាកលវិទ្យាល័យភ្នំពេញអន្តរជាតិក៏នៅមានចំណុចខ្វះខាតខ្លះលើការអនុវត្តការងារកន្លងមកដូចជា៖

- ពុំមានរបាយការណ៍វាយតម្លៃស្តីពីសុវត្ថិភាពទីតាំង
- ពុំមានការសាកល្បងជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រោះមានអាសន្នផ្សេងៗ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិរបស់សាកលវិទ្យាល័យ។

ជារួមមកសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តស្តង់ដា៧លើការបំពេញធនធានរូបវន្តតាមសូចនាករ និងបានបង្ហាញភស្តុតាងគាំទ្របានល្អ។

### ៣. អនុសាសន៍

ដើម្បីកែលម្អការអនុវត្តស្តង់ដានេះឲ្យកាន់តែប្រសើរ ស.ភ.ភ.ព ត្រូវបំពេញ អនុសាសន៍ ដូចខាងក្រោម៖

១. គួរមានរបាយការណ៍វាយតម្លៃស្តីពីសុវត្ថិភាពទាំងខាងក្នុងនិងក្រៅបរិវេណសាកលវិទ្យាល័យ

២. គួរមានការសាកល្បង ជម្លៀសបន្ទាន់ជាក់ស្តែងដើម្បីដោះស្រាយគ្រោះមានអាសន្នផ្សេងៗ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិរបស់សាកលវិទ្យាល័យ។

## ស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុ គឺជាកត្តាសំខាន់សម្រាប់គាំទ្រដល់ការប្រព្រឹត្តទៅ នៃសាកលវិទ្យាល័យទាំងមូលនិងជាកត្តាកំណត់លើភាពជោគជ័យនិងបរាជ័យរបស់គ្រឹះស្ថាន។ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ជាកញ្ចក់មួយក្នុងការឆ្លុះបញ្ចាំងនូវ និរន្តរភាពនៃការអភិវឌ្ឍគុណភាពរបស់សាកលវិទ្យាល័យ។

### ១. ការបំពេញតាមសូចនាករ

១.១. គ្រឹះស្ថានឧត្តមសិក្សាបង្ហាញអំពីស្ថេរភាពហិរញ្ញវត្ថុ ដោយផ្តល់ភស្តុតាងលើភាពគ្រប់គ្រងនៃថវិកាដើម្បីបំពេញតម្រូវការចំណាយលើបុគ្គលិក ប្រតិបត្តិការ និងដើមទុនក្នុងការគាំទ្រដល់កម្មវិធីអប់រំរបស់គ្រឹះស្ថាន

តាមលទ្ធផលនៃរបាយការណ៍ហិរញ្ញវត្ថុរយៈពេលបីឆ្នាំបន្តបន្ទាប់បង្ហាញឲយើញថា ស.ភ.ភ.អ មានលទ្ធភាពធានានិរន្តរភាពហិរញ្ញវត្ថុតាមរយៈប្រភពចំណូលដែលបានពីការបង់ថ្លៃសិក្សារបស់និស្សិត ពីការលក់សេវាកម្ម និង គម្រោងវិនិយោគផ្សេងៗទៀត ដោយសម្រេចបានប្រាក់ចំណេញ ៥៦៨.០៨៥,៨២ដុល្លាក្នុងឆ្នាំ២០១៣ ៨១២.០៨៩,៧៨ដុល្លាក្នុងឆាំ២០១៤ និង២១៣.៥៥៥,៨៩ដុល្លាក្នុងឆ្នាំ២០១៥។ ចំណូលនេះធ្លាក់ចុះជាង៥០%ក្នុងឆ្នាំ២០១៥។

ស.ភ.ភ.អ មិនទាន់មានគម្រោងថវិការនិងវិនិយោគដើម្បីកំណត់អោយបានច្បាស់លាស់អំពីកញ្ចប់ថវិការប្រើប្រាស់ និង ការវិនិយោគដែលត្រូវការចាំបាច់សម្រាប់ទ្រទ្រង់ដំណើរប្រតិបត្តិការនិងការវិនិយោគដើម្បីអភិវឌ្ឍនិងធានាគុណភាពអប់រំរបស់គ្រឹះស្ថានប្រចាំឆ្នាំសិក្សានីមួយៗ។ ប៉ុន្តែកំពុងរៀបចំគម្រោងថវិការ និង ការវិនិយោគនេះសម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៦ទៅ(តាមការពន្យល់ពីប្រធានការិយាល័យនិងហិរញ្ញវត្ថុ)។សាកលវិទ្យាល័យមានគោលការណ៍និងគោលនយោបាយហិរញ្ញវត្ថុរៀបចំឡើងដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាភិបាល និង រៀបរាប់ដោយសង្ខេបពីយន្តការបែងចែង និងគ្រប់គ្រងថវិការ ការគ្រប់គ្រងប្រតិបត្តិការគណនេយ្យចំណូលចំណាយ និងធន ធានបុគ្គលិក ការិយាល័យពាក់ពន្ធ័និងរចនាសម្ព័ន្ធគ្រប់គ្រងនៃការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ។

សាកលវិទ្យាល័យមានគោលនយោបាយនៃការធ្វើនិតិវិធីលទ្ធកម្ម ណែនាំពីគោការណ៍និតិវិធីនិងដំណើរការលទ្ធកម្ម មន្ត្រីលទ្ធកម្ម តួនាទីភារកិច្ចនិងការទទួលខុសត្រូវ។

**១.២. គ្រឹះស្ថានឧត្តមសិក្សាមានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុដឹកនាំដោយប្រធានមួយរូប ដែលត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំទទួលបន្ទុកជាប្រចាំ**

សាកលវិទ្យាល័យមានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុនិងរចនាសម្ព័ន្ធគណនេយ្យ និង ហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានពីររូបទទួលបន្ទុកសម្របសម្រួលកិច្ចការគណនេយ្យនិងហិរញ្ញវត្ថុនិងរាយការណ៍ជូនសាកលវិទ្យាធិការរងនិងសាកលវិទ្យាធិការ។

បុគ្គលិកការិយាល័យហិរញ្ញវត្ថុមានបទពិសោធន៍ និង សមត្ថភាពបំពេញការងារ (តាមការអះអាងរបស់ប្រធានការិយាល័យ ប៉ុន្តែមិនបានបង្ហាញឯកសារផ្លូវការគ្រប់គ្រាន់បញ្ជាក់កម្រិតបទពិសោធន៍ កម្រិតគុណវុឌ្ឍិ និងការបណ្តុះបណ្តាលពង្រឹងសម្ថភាពបុគ្គលិក។

**១.៣. គ្រឹះស្ថានឧត្តមសិក្សារៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានពិពណ៌នាលម្អិតអំពីចំណូល និងចំណាយ តាមផ្នែក និងមានចែងអំពីថវិកាបម្រុងសម្រាប់ការចំណាយផ្សេងៗ**

ស.ភ.ភ.អ មិនបានបង្ហាញឯកសារលម្អិតនៃគម្រោងថវិកាក៏ដូចជាហិរញ្ញវត្ថុជាផ្លូវការប្រចាំសម្រាប់អនុវត្តក្នុងឆ្នាំនីមួយៗ។ ប៉ុន្តែមានការប្រជុំគណៈគ្រប់គ្រងនិងផ្នែកពាក់ព័ន្ធដើម្បីដំណើរការរៀបចំគម្រោងនេះសម្រាប់អនុវត្តពីឆ្នាំ២០១៦ទៅ។

**១.៤. តំណាងមកពីមហាវិទ្យាល័យឬដេប៉ាតឺម៉ង់ និង ផ្នែកពាក់ព័ន្ធផ្សេងៗរបស់គ្រឹះស្ថានមានឱកាសចូលរួម រៀបចំផែនការថវិកា**

ស.ភ.ភ.អ មិនបានបង្ហាញឯកសារនៃការចូលរួមពីមន្ត្រីពាក់ពន្ធ័ក្នុងការចូលរួមរៀបចំគម្រោងថវិការនិងហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានអនុវត្តកន្លងមក។ ប៉ុន្តែមានកំណត់ហេតុប្រជុំដែលមានសមាសភាពថ្នាក់ដឹកនាសាកលវិទ្យាល័យចូលរួមក្នុងការរៀបចំគម្រោងថវិការនិងហិរញ្ញវត្ថុសម្រាប់ពីឆ្នាំ២០១៦

**១.៥. គ្រឹះស្ថានឧត្តមសិក្សាធ្វើសវនកម្មជាប្រចាំ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការមានឋានៈស្មើ**

ស.ភ.ភ.អ មិនទាន់មានផ្នែកឬគណៈកម្មការសវនកម្មផ្ទៃក្នុងគិតទាំងរចនាសម្ព័ន្ធ និង ធនធានបុគ្គលិក និងយន្តការសវកម្មដើម្បីធានានិរន្តរភាពនិងតម្លាភាពនៃការគ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុ ការគ្រប់គ្រងចំនូល ចំណាយនិងរាយការណ៍ចូលថ្នាក់ដឹកនាំសាកលវិទ្យាល័យជាប្រចាំ ប៉ុន្តែ ស.ភ.ភ.អ

មានគម្រោងបង្កើតផ្នែកសវនកម្មនិងដំណើរការក្នុងឆ្នាំ២០១៦នេះ(តាមការពន្យល់របស់ប្រធានការិយាល័យនិងហិរញ្ញវត្ថុ)។

**១.៦. គ្រឹះស្ថានឧត្តមសិក្សាសាធារណៈបញ្ជូនផែនការយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅក្រសួងអាណាព្យាបាលនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមកាលបរិច្ឆេទកំណត់**

គ្រឹះស្ថានឧត្តមសិក្សាសបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍប្រចាំឆ្នាំ និង បាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមកាលបរិច្ឆេទកំណត់(មិនតម្រូវ ស.ភ.ភ.អ ដែលជាគ្រឹះស្ថានឧត្តមសិក្សាឯកជន)

**១.៧. គ្រឹះស្ថានឧត្តមសិក្សាឯកជនបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ របាយការណ៍សវនកម្ម និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។**

សាកលវិទ្យាល័យបានបញ្ជូនឯកសារផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។ មិនមានរបាយការណ៍សវនកម្មបញ្ជូនទៅក្រុមប្រឹក្សាភិបាលដោយ ស.ភ.ភ.អ ទើបតែចាប់គម្រោងរៀបចំបង្កើតគោលការណ៍និងយន្តការអនុវត្តសវនកម្មផ្ទៃក្នុង។

## ២. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ(២០១៣ ដល់ ២០១៥)ស.ភ.ភ.អ រក្សាបានស្ថិរភាពហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ដំណើរប្រតិបត្តិការបណ្តុះបណ្តាល និង សិក្សាស្រាវជ្រាវ បើទោះបីជានិស្សិតចុះឈ្មោះសិក្សាបានធ្លាក់ចុះទាបក្នុងរយៈបីឆ្នាំសិក្សានេះ។ ស.ភ.ភ.អ មិនបានបង្ហាញច្បាស់លាស់ពីគម្រោងថវិការ និងហិរញ្ញវត្ថុរបស់ខ្លួនពិសេសក្នុងការធានាស្ថិរភាព និង និរន្តរភាពនៃដំណើរការបណ្តុះបណ្តាល និងការវិនិយោគដើម្បីអភិវឌ្ឍន៍ និង ធានាគុណភាពសិក្សាអប់រំ ដូចជាគម្រោងថវិការសម្រាប់ស្រាវជ្រាវ អភិវឌ្ឍន៍សមត្ថភាពគ្រូ និង មូលដ្ឋានសម្ភារៈរូបវន្តជាច្រើនទៀតគិតទាំងបណ្ណាល័យផងដែរបើទោះបីជាមានការអះអាងពីគណៈគ្រប់គ្រង និង អ្នកពាក់ពន្ធ័ថាសាកលវិទ្យាល័យបានធ្វើការវិភាជន៍ថវិការក្នុងការធានានិរន្តរភាព និង ការអភិវឌ្ឍន៍សាកលវិទ្យាល័យ ពិសេសគម្រោងអភិវឌ្ឍន៍បណ្ណាល័យថ្មីកម្រិតស្តង់ដារអន្តរជាតិកំពុងសាងសង់នៅជាន់ទី៧មិនបានបញ្ចូលក្នុងគម្រោងថវិការសាកលវិទ្យាល័យទេ។ ចំណែកឯគម្រោងថវិការនិងហិរញ្ញវត្ថុថ្មីសម្រាប់អនុវត្តពីឆ្នាំ២០១៦ទៅ កំពុងស្ថិតក្នុងដំណើរការរៀបចំជាមួយនឹងការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៦-២០២០។ ទោះបីជាសាកលវិទ្យាល័យបាននិង

កំពុងដំណើរការបណ្តុះបណ្តាលរយៈពេលជាង១០ឆ្នាំនេះប្រកបដោយភាពរលូនក៏ដោយ ក៏សាកលវិទ្យាល័យនៅមានចំណុចខ្វះខាតខ្លះៗដូចខាងក្រោមៈ

- មិនបានរៀបចំគម្រោងថវិកានិងវិនិយោគដែលត្រូវការចាំបាច់សម្រាប់ទ្រទ្រង់ដំណើរប្រតិបត្តិការបណ្តុះបណ្តាលអភិវឌ្ឍនិងធានាគុណភាពអប់រំរបស់គ្រឹះស្ថានប្រចាំឆ្នាំសិក្សានីមួយៗ មានដូចជាគម្រោងថវិកាសម្រាប់ស្រាវជ្រាវ បណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពគ្រូ។
- មិនទាន់មានផ្នែកឬគណៈកម្មការសវនកម្មផ្ទៃក្នុងគិតទាំងរចនាសម្ព័ន្ធ ធនធានបុគ្គលិកនិងយន្តការសវនកម្មដើម្បីធានានិរន្តរភាពនិងតម្លាភាពនៃការគ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងចំនូលចំណាយគ្រប់ផ្នែក។
- ឯកសារបទដ្ឋានគតិយុត្តិពាក់ពន្ធ័ភាគច្រើនមិនទាន់មានលក្ខណៈផ្លូវការដោយខ្វះហត្ថលេខាឯកភាពពីសាកលវិទ្យាធិការឬប្រធានក្រុមប្រឹក្សាភិបាល មិនមានចុះកាលបរិច្ឆទត្រឹមត្រូវនិងត្រាសាកលវិទ្យាល័យ។

៣. អនុសាសន៍

១.ត្រូវរៀបចំគម្រោងថវិកានិងវិនិយោគសម្រាប់ទ្រទ្រង់ដំណើរប្រតិបត្តិការបណ្តុះបណ្តាលអភិវឌ្ឍនិងធានាគុណភាពអប់រំរបស់គ្រឹះស្ថានប្រចាំឆ្នាំសិក្សានីមួយៗ។

២.ត្រូវបង្កើតផ្នែកឬគណៈកម្មការសវនកម្មផ្ទៃក្នុងគិតទាំងរចនាសម្ព័ន្ធ ធនធានបុគ្គលិកនិងយន្តការសវកម្មដើម្បីនិងធ្វើរបាយការណ៍សវនកម្មជូនសាកលវិទ្យាធិការនិងក្រុមប្រឹក្សាភិបាលជាប្រចាំ។

៣.ត្រូវរៀបចំឯកសារពាក់ពន្ធ័ទាំងអស់ឲស្របតាមបទដ្ឋានគតិយុត្តិដោយមានចុះហត្ថលេខាឯកភាព ពីសាកលវិទ្យាធិការឬប្រធានក្រុមប្រឹក្សាភិបាល ចុះលេខ ចុះកាលបរិច្ឆទត្រឹមត្រូវ និង មានត្រាសាកលវិទ្យាល័យ។

**ស្តង់ដា៩ ៖ ការធានាគុណភាពផ្ទៃក្នុង**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានផ្តោតចិត្តទុកដាក់ជាចំបងលើគុណភាពនៃការបង្រៀន ការសិក្សា ស្រាវជ្រាវ និង សេវាកម្ម។ គោលដៅរបស់សាកលវិទ្យាល័យគឺបង្កើតបរិស្ថានសិក្សាមួយដ៏ស្វាហាប់ និងមានន័យប្រកបដោយភាពច្នៃប្រឌិត និងវគ្គបណ្តុះបណ្តាលបទបញ្ញត្តិផ្សេងៗ ដែលផ្តល់នូវគុណភាពអប់រំ ដើម្បីធានាថានិស្សិតនឹងទទួលបានទាំងជំនាញរឹងនិងជំនាញទន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងស្តង់ដាររស់នៅ នៅក្នុងសហគមន៍អាស៊ាននាពេលអនាគត។ ក្នុងន័យនេះ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តតាមស្តង់ដា និង បានបំពេញនូវសូចនាករដូចខាងក្រោមៈ

**១. ការបំពេញតាមសូចនាករ**

**១.១. គ្រឹះស្ថានឧត្តមសិក្សាមានប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ដោយមានគោលការណ៍ណែនាំ និង នីតិវិធីច្បាស់លាស់**

ដើម្បីរក្សាបាននិរន្តរភាពនៃការពង្រឹងគុណភាពគណៈគ្រប់គ្រងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ទទួលស្គាល់ពីសារៈសំខាន់នៃស្ថាប័នភាវូបនីយកម្មនៃការធានាគុណភាពផ្ទៃក្នុង។ ជាលទ្ធផលពួកគេទទួលបានការអនុម័តយល់ព្រមបង្កើតអង្គភាពធានាគុណភាពផ្ទៃក្នុងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIUIQA) ដែលមានបេសកកម្ម គឺស្ថាបនាវប្បធម៌នៃការពង្រឹងគុណភាពនៃការអប់រំជាបន្តបន្ទាប់នៅក្នុងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ។ សាកលវិទ្យាល័យបានបង្កើតគោលការណ៍ណែនាំ និងនីតិវិធីក្នុងការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុង រួមមានគណៈកម្មការធានាគុណភាពផ្ទៃក្នុង រចនាសម្ព័ន្ធ ការិយាល័យធានាគុណភាពផ្ទៃក្នុង និងបំណែងចែកតួនាទីភារកិច្ច។

## ១.២. ដំណើរការធានាគុណភាពអប់រំមានការចូលរួម និងសហការពីគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ រួមទាំង បុគ្គលិក និស្សិត និងភាគីពាក់ព័ន្ធ

គណៈគ្រប់គ្រងសាកលវិទ្យាល័យមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការធានានិងលើកកម្ពស់គុណភាពអប់រំ ដូចនេះដំណើរការធានាគុណភាពអប់រំមានការចូលរួមពីក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធានការិយាល័យ និងប្រធានផ្នែកទាំងក្នុងសាកលវិទ្យាល័យនិងពីស្ថាប័នឧបសម្ព័ន្ធ។

## ១.៣. ប្រព័ន្ធធានាគុណភាពអប់រំប្រកាសឱ្យប្រើប្រាស់ និង ទទួលបានការគាំទ្រពីថ្នាក់ដឹក នាំកំពូលរបស់គ្រឹះស្ថានឧត្តមសិក្សាដើម្បីធានាប្រសិទ្ធភាព និង និរន្តរភាពនៃការអនុវត្ត

ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្ត ថ្នាក់ដឹកនាំសាកលវិទ្យាល័យមានការគាំទ្រ និងប្រកាសដាក់ឲ្យប្រើប្រាស់គោលការណ៍ណែនាំ និង នីតិវិធីសម្រាប់អនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុងរបស់សាកលវិទ្យាល័យ។

## ១.៤. គ្រឹះស្ថានឧត្តមសិក្សាផ្តល់ធនធានគ្រប់គ្រាន់ សម្រាប់បង្កើត និងគាំទ្រប្រព័ន្ធធានាគុណភាពអប់រំប្រកបដោយប្រសិទ្ធភាព

តាមរយៈការិយាល័យធានាគុណភាពផ្ទៃក្នុង សាកលវិទ្យាល័យបានខិតខំក្នុងការផ្តល់ធនធានទាំងធនធានហិរញ្ញវត្ថុ សម្ភាររូបវន្ត និងធនធានមនុស្សលើការបណ្តុះបណ្តាលសមត្ថភាពបន្ថែម ក្នុងកិច្ចគាំទ្រដល់ប្រព័ន្ធធានាគុណភាព។ ការិយាល័យធានាគុណភាពផ្ទៃក្នុង បានរៀបចំខ្ទង់ចំនាយ ដែលស្នើសុំចំណាយដោយផ្នែកធានាគុណភាពផ្ទៃក្នុង សម្រាប់ដំណើរការប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

### ១.៥. លទ្ធផលស្វ័យវាយតម្លៃត្រូវយកទៅប្រើប្រាស់ និង បញ្ចូលទៅក្នុងផែនការលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍

សាកលវិទ្យាល័យបានធ្វើការលើដំណើរការស្វ័យវាយតម្លៃការងារ វាយតម្លៃគុណភាពបង្រៀន និងគុណភាពរៀនរបស់និស្សិត ព្រមទាំងមានការធ្វើតេស្តលើសមត្ថភាពរបស់គ្រូបង្រៀន វាស់ស្ទង់កម្រិតចំណេះដឹង និងចំណុចខ្វះខាត ដើម្បីងាយស្រួលក្នុងការកែតម្រូវ បំប៉នបន្ថែម។ លើសពីនេះ លទ្ធផលវាយតម្លៃនាឆ្នាំកន្លងមករបស់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានពីការវាយតម្លៃរបស់ គ.ទ.ក នោះសាកលវិទ្យាល័យបានយកមកកែលម្អនិងអភិវឌ្ឍន៍ជាបន្តបន្ទាប់។

### ១.៦. គ្រឹះស្ថានឧត្តមសិក្សា រៀបចំចងក្រងសៀវភៅណែនាំ ស្តីពី ការធានាគុណភាពអប់រំផ្ទៃក្នុង

ដើម្បីធានាបានប្រសិទ្ធភាពលើការអនុវត្តការងារធានាគុណភាពផ្ទៃក្នុងការិយាល័យធានាគុណភាពផ្ទៃក្នុងបានរៀបចំចងក្រងសៀវភៅណែនាំស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុងព្រមទាំងស្នើសុំការគាំទ្រ និងអនុម័តដាក់ឲ្យប្រើប្រាស់ដោយថ្នាក់ដឹកនាំរបស់សាកលវិទ្យាល័យ។ អត្ថន័យនៃពាក្យគុណភាពនៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិត្រូវបានបកប្រែថា "សមស្របនឹងគោលបំណង" និង"អនុលោមតាមតម្រូវការ" ។ ឃ្លាដែលថា "សមស្របនឹងគោលបំណង" ផ្តល់ឲ្យគណៈគ្រប់គ្រង នូវភាពបត់បែន ទៅតាមមាគ៌ាដើម្បីសម្រេចបានគុណភាពដោយពឹងផ្អែកលើគោលបំណងដែលបានកំណត់ជាក់លាក់។ "អនុលោមតាមតម្រូវការ" សំដៅដល់ទស្សនៈគំនិតដែលសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិដើម្បីឆ្លើយតបឬអនុលោមតាមស្តង់ដាដែលកំណត់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(ACC) និង គោលការណ៍ណែនាំកំណត់ដោយក្រសួងអប់រំយុវជន និងកីឡា (MoEYS)។

## ២. សេចក្តីសន្និដ្ឋាន

ចាប់តាំងពីការចាប់ផ្តើមបង្កើតជាលើកដំបូងមកសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានចាត់ទុកគុណភាពជាអាទិភាពដំបូងគេរបស់ខ្លួន។ បេសកកម្មរបស់សាកលវិទ្យាល័យគឺអភិវឌ្ឍមេដឹកនាំ និងសហគ្រិនឲ្យមានសមត្ថភាពនិងប្រកបដោយការទទួលខុសត្រូវនៅក្នុងសង្គមដែលអ្នកទាំងអស់នេះនឹងចូលរួមចំណែកអភិវឌ្ឍប្រទេស និង ក្នុងតំបន់របស់យើងប្រកបដោយប្រសិទ្ធភាព។ នៅក្នុងការរៀបចំដំណើរការធានាគុណភាពផ្ទៃក្នុងសាកលវិទ្យាល័យបានដាក់ចេញជាគោលនយោបាយមួយច្បាស់ លាស់ សំដៅធានាដល់ការរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព និង មានការចូលរួមពីគ្រប់ភាគីពាក់

ព័ន្ធលើដំណើរការធានាគុណភាព។ ទន្ទឹមនឹងការមានចំណុចល្អប្រសើរជាច្រើននោះសាកលវិទ្យាល័យភ្នំពេញអន្តរជាតិក៏នៅមានចំណុចខ្វះខាត ដែលពុំទាន់បានអនុវត្តក្នុងការវាយតម្លៃមន្ត្រីធានាគុណភាពផ្ទៃក្នុងលើការអនុវត្តការងារនាពេលកន្លងមកដើម្បីធានាឲ្យបានប្រសិទ្ធភាពនៃដំណើរការពិនិត្យតាមដាន និងវាយតម្លៃ។ ជារួមមកសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានអនុវត្តស្តង់ដារទី៩ លើការងារធានាគុណភាពផ្ទៃក្នុង និងបានបំពេញសូចនាករ ព្រមទាំងបានបង្ហាញភស្តុតាងគាំទ្របានល្អ។

### ៣. អនុសាសន៍

១.គួររៀបចំការវាយតម្លៃលើមន្ត្រីធានាគុណភាពផ្ទៃក្នុង ដើម្បីធានាឲ្យការអនុវត្តការងារគុណភាពផ្ទៃក្នុងកាន់តែមានសុក្រិតភាព ឯករាជ្យភាពលើការពិនិត្យតាមដាននិង ប្រសិទ្ធភាពការងារខ្ពស់

២.គួររៀបចំផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៦ (Annual Budget Projection) សម្រាប់ការធានា គុណភាពផ្ទៃក្នុងដោយឡែក ព្រមទាំងមានការយល់ព្រម ឯកភាពលើការចំនាយពីគណៈគ្រប់គ្រង។

## IV. សេចក្តីសន្និដ្ឋានរួម

ផ្អែកលើលទ្ធផលនៃការវាយតម្លៃរបស់ក្រុមមន្ត្រីវាយតម្លៃលើស្ថានភាពជាក់ស្តែងនៃការអនុវត្តស្តង់ដាជាតិទាំង៩និងបន្ទាប់ពីការធ្វើបទបង្ហាញអំពីលទ្ធបឋមជូនដល់គណៈគ្រប់គ្រងនិងមន្ត្រីពាក់ព័ន្ធនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ យើងពិនិត្យឃើញសាកលវិទ្យាល័យនេះ សម្រេចបានសមិទ្ធិផលគួរជាទីចាប់អារម្មណ៍ក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍សាកលវិទ្យាល័យស្របតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រដែលបានអនុវត្តន៍ក្នុងរយៈពេល១៩ឆ្នាំកន្លងទៅនេះ ពិសេសដំណើរការបណ្តុះបណ្តាលក៏ដូចជាការអភិវឌ្ឍធនធានមនុស្សស្របតាមស្តង់ដាជាតិ ទាំង៩ ដោយអនុវត្តន៍បានលទ្ធផលល្អ ភាគច្រើនលើស្តង់ដានីមួយៗ បើទោះបីជាក្រុមមន្ត្រីវាយតម្លៃ បាន រកឃើញមានចំនុចខ្វះខាតខ្លះៗ ដែលចាំបាច់ត្រូវធ្វើការកែលម្អដើម្បីឲ្យប្រសើរឡើង និង ធានាបានប្រសិទ្ធិភាព និងនិរន្តរភាពនៃដំណើរការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយសមត្ថភាព និងគុណសម្បត្តិប្រកួតប្រជែងទាំងកម្រិតជាតិនិងតំបន់។ ចំនុចល្អ ចំនុចខ្វះខាត និង អនុសាសន៍ក៏ដូចជាសំណូមពរ លើការអនុវត្តស្តង់ដាទាំង៩ ។ **ស.ភ.ភ.អ** អនុវត្តន៍បានល្អភាគច្រើនក្នុងការបំពេញសូចនាករលម្អិតទាំង**៧២***(សូចនាករ៦នៃ ស្តង់ដា៨ មិនតម្រូវសម្រាប់គ្រឹះស្ថានឯកជន)* នៃ **ស្តង់ដាទាំង៩**

ទោះបីជា ស.ភ.ភ.អ មានចំណុចល្អភាគច្រើនក្នុងការអនុវត្តក៏ដូចជាការបំពេញបានសូចនាករនៃស្តង់ដាទាំង៩ស្ទើរទាំងអស់ តែក្រុមមន្ត្រីវាយតម្លៃយើងបានរកឃើញមានចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តស្តង់ដាទាំង៩នេះរួមមាន៖

១.ឯកសារបទដ្ឋានគតិយុត្តមួយចំនួនដែលគាំទ្រស្តង់ដាទាំង៩មានការខ្វះខាតតាមបែបបទរដ្ឋបាលដូចជា៖ មិនបានកំណត់ច្បាស់លាស់ពីកាលបរិច្ឆេទ ឈ្មោះហត្ថលេខី ប្រថាប់ត្រា និងចុះលេខលិខិតបទដ្ឋាន និងលេខទំព័រជាដើម បើទោះបីជាគណៈគ្រប់គ្រងបានអះអាងថាលិខិតបទដ្ឋាន គតិយុត្តផ្ទៃក្នុងភាគច្រើនមិនចាំបាច់មានហត្ថលេខា កាលបរិច្ឆេទ ឬ ប្រថាប់ត្រាទេព្រោះនេះជាវប្បធម៌របស់សាកលវិទ្យាល័យ(**ស្តង់ដាទាំង៩**)។

២ ពុំមានរបាយការណ៍ប្រចាំឆ្នាំ២០១២ និង ២០១១ ស្តីពីការវាយតម្លៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាលរបស់ខ្លួន(**ស្តង់ដា២**)។

៣ កិច្ចសន្យាគ្រូបង្រៀនមួយចំនួនមិនមានកាលបរិច្ឆេទចុះកិច្ចសន្យា មិនមានស្ថិតិស្តីពីការផ្លាស់ប្តូរគ្រូប្រចាំឆ្នាំ លទ្ធផលនៃការវាយតម្លៃគ្រូមិនបានពិគ្រោះយោបល់ជាមួយគ្រូឲ្យបានទូលំទូលាយ ដើម្បីធ្វើការកែលម្អនិងអភិវឌ្ឍន៍ឲ្យប្រសើរឡើង ការណែនាំ និង ផ្សព្វផ្សាយគោលការណ៍និងនិតិវិធីដែលគាំទ្រដល់ការស្រាវជ្រាវទៅបុគ្គលិក និង គ្រូបង្រៀននៅមានកម្រិត (**ស្តង់ដា៣**)។

៤ ពុំមានកំណត់គោលការណ៍ និង និតិវិធីច្បាស់លាស់ ក្នុងការជ្រើសរើសសមាជិកគណៈកម្មការ អភិវឌ្ឍកម្មវិធីសិក្សា (**ស្តង់ដា៤**)។

៥.ពុំមានឯកសារគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីស្ថិតិនៃស្ថានភាពនិស្សិតសិក្សានិងបោះបង់ការសិក្សាជារៀងរាល់ឆមាសនិងឆ្នាំសិក្សានីមួយៗ មិនទាន់មានគោលការណ៍ស្តីពីនិតិវិធីដោះស្រាយបណ្តឹងតវ៉ានិងការដាក់ពិន័យចំពោះការប្រព្រឹត្តល្មើស នឹង វិធានវិន័យនិស្សិត (**ស្តង់ដា៥**)។

៦ បណ្ណាល័យបច្ចុប្បន្នមានលក្ខណៈតូចចង្អៀត និង មានគ្រប់គ្រាន់នូវឯកសារយោង ទស្សនាវដ្តី វិទ្យាសាស្ត្រ និង សម្ភារសិក្សាផ្សេងៗដែលគាំទ្រដល់កម្មវិធីសិក្សាដែលកំពុងអនុវត្តធនធាន សិក្សាតាមតាមប្រព័ន្ធអេឡិចត្រូនិចនៅមានកម្រិត ស.ភ.ភ.អ មិនបានបញ្ជាក់ពីផែនការអភិវឌ្ឍ បណ្ណាល័យសម្រាប់រយៈពេលវែង ប៉ុន្តែបណ្ណាល័យថ្មីដែលកំពុងដំណើរការអភិវឌ្ឍន៍នៅជាន់ទី៧ ស្ថិក្រោមគម្រោងអភិវឌ្ឍរបស់ក្រុមហ៊ុន JCMK Group មិនមែនជាគម្រោងវិនិយោគរបស់ ស.ភ. ភ .អ ទេ (**ស្តង់ដា៦**)។

៧ ពុំមានរបាយការណ៍វាយតម្លៃស្តីពីសុវត្ថិភាពនិងការជម្លៀសបន្ទាន់គ្រាមានសន្ទ(**ស្តង់ដា៧**)។

៨ មិនបានរៀបចំគម្រោងថវិកា និង គម្រោងវិនិយោគ ដែលត្រូវការចាំបាច់សម្រាប់គាំទ្រដំណើរ

ការបណ្តុះបណ្តាល ការអភិវឌ្ឍ និងការធានាគុណភាពអប់រំប្រចាំឆ្នាំសិក្សានីមួយៗដូចជាគម្រោង ថវិកា សម្រាប់កម្មវិធីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍសមត្ថភាពគ្រូ មិនមានគណៈកម្មការសវនកម្មផ្ទៃក្នុង និង មិនបានអនុវត្តពេញលេញការងារសវនកម្មរបស់ខ្លួន(ស្តង់ដា៨)។

៩ ពុំមានការវាយតម្លៃលើមន្ត្រីធានាគុណភាពផ្ទៃក្នុង និងពុំមានផែនការថវិកាសម្រាប់ការធានាគុណភាពផ្ទៃក្នុងដែលបានអនុម័តនិងសម្រេចដោយគណៈគ្រប់គ្រងសាកលវិទ្យាល័យ (ស្តង់ដា៩)។

## V. អនុសាសន៍

ដោយអនុវត្ត និង បំពេញតាមសូចនាករនៃស្តង់ដាទាំង៩ នៅមានចំនុចខ្វះខាតមួយចំនួនដូចរៀបរាប់ ខាងលើ នោះមន្ត្រីវាយតម្លៃបានសម្រេចផ្តល់នូវអនុសាសន៍សម្រាប់គណៈគ្រប់គ្រង ក៏ដូចជាមន្ត្រីពាក់ពន្ធ័ទាំងអស់នៃ ស.ភ.ភ.អ ដើម្បីធ្វើការកែលម្អឲ្យកាន់តែប្រសើរឡើងនូវចំនុចខ្វះខាតទាំងនេះ ហើយអនុសាសន៍ផ្តល់ដោយក្រុមមន្ត្រីវាយតម្លៃរួមមាន៖

១. គួររៀបចំឯកសារបទដ្ឋានគតិយុត្តមួយចំនួនឲ្យសមស្របតាមបែបបទរដ្ឋបាល

២. ត្រូវមានរបាយការណ៍វាយតម្លៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាលជារៀងរាល់ឆ្នាំ

៣. កិច្ចសន្យាគ្រូបង្រៀនគួរបញ្ជាក់ពីកាលបរិច្ឆេទចុះកិច្ចសន្យា គួរមានស្ថិតិស្តីពីការផ្លាស់ប្តូរគ្រូប្រចាំ ឆ្នាំ ហើយលទ្ធផលនៃការវាយតម្លៃគ្រូគួរផ្តល់ការពិគ្រោះយោបល់ដោយមានការពិភាក្សាទាំងសង ខាងដើម្បីកែលម្អនិងអភិវឌ្ឍគ្រូបង្រៀនឲ្យបានគ្រប់ៗគ្រូទាំងអស់និងគួរការផ្តល់ណែនាំអំពីគោល ការណ៍ និងនីតិវិធីដែលគាំទ្រដល់ការស្រាវជ្រាវដល់បុគ្គលិក និងគ្រូបង្រៀនទាំងអស់។

៤. គួរបញ្ជាក់ពីយុទ្ធសាស្ត្រដែលគាំទ្រដល់ការស្រាវជ្រាវ ឲ្យស្របតាមបេសកកម្មរបស់ខ្លួននិងបញ្ជាក់ពីមូលដ្ឋានសម្ភារៈនិងថវិកាដែលគាំទ្រដល់ការស្រាវជ្រាវរបស់សាកលវិទ្យាល័យ

៥. គួរកំណត់គោលការណ៍ និង នីតិវិធីក្នុងការជ្រើសរើសគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាឲ្យបាន ច្បាស់លាស់។

៦. គួរមានបញ្ជីស្ថិតិស្តីពីស្ថានភាពនិស្សិតសិក្សា និង បោះបង់ការសិក្សាតាមឆមាស និង ឆ្នាំសិក្សា នីមួយៗ និង គួរមានមានគោលការណ៍ស្តីពីនិតិវិធីដោះស្រាយបណ្តឹងតវ៉ា និងការដាក់ពិន័យចំពោះការប្រព្រឹត្តល្មើសនឹងវិធានវិន័យនិស្សិត។

៧. គួរបន្ថែមឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និង សម្ភារសិក្សាផ្សេងៗដែលគាំទ្រដល់កម្មវិធី សិក្សាកំពុងដំណើរការដំណើរការទាំងអស់ គួរបន្ថែមធនធានសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចនិង គួរមានផែនការអភិវឌ្ឍបណ្ណាល័យសម្រាប់រយៈពេលវែង។

៨. គួរមានរបាយការណ៍វាយតម្លៃស្តីពីសុវត្ថិភាព ការសោកល្បង និង ការជម្លៀសបន្ទាន់គ្រោះ

៨. គួរមានរបាយការណ៍វាយតម្លៃស្តីពីសុវត្ថិភាព ការរសាកល្បង និង ការរជម្លៀសបន្ទាន់គ្រាមាន អាសន្ន។

៩. ត្រូវរៀបចំគម្រោងថវិកានិងគម្រោងវិនិយោគដែលត្រូវការចាំបាច់សម្រាប់គាំទ្រដំណើរការបណ្តុះបណ្តាល ការអភិវឌ្ឍ និងការធានាគុណភាពអប់រំប្រចាំឆ្នាំសិក្សានីមួយៗ និង ត្រូវមានគណៈកម្មការសវនកម្មផ្ទៃក្នុង និងគួរអនុវត្តការងារសវនកម្មផ្ទៃក្នុងឲ្យបានពេញលេញនិងទៀងទាត់។

១០.គួររៀបចំការវាយតម្លៃមន្ត្រីធានាគុណភាពផ្ទៃក្នុងនិងត្រូវមានផែនការថវិកាសម្រាប់ការធានាគុណភាពផ្ទៃក្នុងដែលអនុម័តនិងសម្រេចដោយគណៈគ្រប់គ្រងសាកលវិទ្យាល័យ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៦

ប្រធានក្រុមមន្ត្រីវាយតម្លៃ